**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការអភិវឌ្ឍការចិញ្ចឹមសត្វ នៅប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ៖ **កញ្ញា ស៊ឹម សុគន្ធា**

**កញ្ញា លី មុយគីម**

ណែនាំដោយ

សាស្ត្រាចារ្យរងបណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី **០៨**

ឆ្នាំចូលសិក្សា **២០២០**

ឆ្នាំសរសេរសារណា **២០២៤**

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមយើងខ្ញុំជានិស្សិតឈ្មោះ **ស៊ឹម សុគន្ធា** និង **លី មុយគីម** ដែលសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ៨ ក្រុម D4C1 នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

យើងខ្ញុំសូមគោរពថ្លែងអំណរអរគុណនិងសម្តែងនូវកតញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក **ស៊ឹម ម៊ូ** លោកឪពុក **លី សុវណ្ណានី**

អ្នកម្តាយ **ហ៊ុយ ចាន់ដារ៉ា** អ្នកម្តាយ **តាំង ម៊ុនឡាង**

ជាដំបូងយើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់លោកអ្នកមានគុណ ចំពោះលោកឪពុក និង អ្នកម្តាយដែលបានចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់ដំបូន្មានល្អៗ ជាពិសេសបានជួយទំនុកបម្រុងគាំទ្រដល់ការសិក្សាតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់បរិញ្ញាបត្រ។ មិនត្រឹមតែប៉ុណ្ណោះលោកទាំងពីរបានបញ្ចេញកម្លាំងកាយ ចិត្ត ហត់នឿយគ្រប់បែបយ៉ាងដើម្បីបានថវិកាមកផ្គត់ផ្គង់ដល់ការសិក្សារបស់កូនៗ។ គុណដ៏ធំធេងដែលមិនអាចកាត់ថ្លៃបាននេះ កូននឹងចងចាំទុកនិងប្តេជ្ញាចិត្តថានិងមិនធ្វើអោយលោកទាំងពីរអស់សង្ឃឹមឡើយ ដោយកូនៗនិងខិតខំប្រឹងប្រែងរៀនសូត្រអោយសមនិងតម្លៃ និងធ្វើជាកូនល្អសម្រាប់គ្រួសារ មិត្តល្អ សិស្សល្អ និងពលរដ្ឋល្អសម្រាប់សង្គមជាតិនាពេលអនាគត។

ឯឧត្តមនៃសាកលវិទ្យាសាកលវិទ្យាធិការ សាកលវិទ្យាការរង ព្រឹតបុរស នាយកថ្នាក់ក្រោមបរិញ្ញាបត្រ ប្រធានការិយាល័យ និងបុគ្គលិកសិក្សា ព្រមទាំងសាស្រ្តចារ្យគ្រប់មុខវិជ្ជាទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិស្រាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានផ្តល់ការអប់រំ និងចំណេះដឹងជាច្រើនកន្លងមកដល់កូនសិស្សដើម្បីជាស្ពានឈានទៅរកភាពជោគជ័យនាពេលអនាគត។

លោកសាស្រ្តចារ្យរង បណ្ឌិត **ឈុន ពហុ** ដែលបានខិតខំបង្ហាត់បង្រៀននិងណែនាំ ជួយជ្រោមជ្រែងដឹកនាំកន្លងមកនេះ និងបាននាំយកនូវឯកសារល្អៗមកដល់យើងខ្ញុំ។ មិនត្រឹមតែប៉ុណ្ណោះបានផ្តល់នូវគំនិតល្អៗក្នុងការរៀបចំក្នុងការសរសេរសារណាមួយនេះ និងបានកែសម្រួលនូវចំណុចខ្វះខាតចាប់តាំងពីចំណុចចាប់ផ្តើមមកដល់ទីបញ្ចប់រហូតទទួលបានជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ និងមិត្តនិស្សិតទាំងអស់គ្នាទទួលបាននូវពរទាំងបួន សម្បត្តិបី អរិយទ្រព្យទាំងប្រាំពី និងមានសេចក្តីសុខសំណាងល្អធ្វើដំណើរប្រកបដោយសុខសុវត្ថិភាពគ្រប់ពេលវេលា គ្រប់ទីកន្លែងកុំបីខានឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានសិក្សាលើថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ យើងខ្ញុំបានសិក្សាស្វែងយល់អំពីមេរៀន ទ្រឹស្តី និងការស្រាវជ្រាវជាច្រើនដែលបានឆ្លុះបញ្ចាំងពីការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ជាពិសេសដោយមើលឃើញថាការចិញ្ចឹមសត្វជាផ្នែកមួយដែលបានជួយលើកតម្កើងជីវភាពរបស់ប្រជាជន ហើយក៏ជាបញ្ហាសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសផងដែរនោះ ទើបក្រុមយើងខ្ញុំបានធ្វើការចុះស្រាវជ្រាវ និងរៀបចំចងក្រងជារបាយការណ៍កម្មសិក្សាមួយស្តីពី **“ការអភិវឌ្ឍការចិញ្ចឹមសត្វនៅប្រទេសកម្ពុជា”** ។

ចំពោះកម្រងឯកសារស្រាវជ្រាវ ដែលអ្នកកំពុងកាន់នឹងដៃនេះ ជាសមិទ្ធផលមួយដែលឆ្លងកាត់ការស្រាវជ្រាវពីសំណាក់ឯកសារស្រាវជ្រាវ ពីសំណាក់កម្រង់ឯកសារជាច្រើន រួមនឹងការតម្រង់ទិសពិសំណាក់លោកសាស្រ្តចារ្យរង បណ្ឌិត **ឈុន ពហុ** ដែលបានផ្តល់នូវគំនិតសំខាន់ៗដែលជាគន្លឹះនៃការស្រាវជ្រាវប្រធានបទនេះផងដែរ។ ចំពោះការសិក្សាស្រាវជ្រាវពីប្រធានបទខាងលើ បានផ្តល់នូវចំណេះដឹងបន្ថែមដល់យើងខ្ញុំ និងយល់ កាន់តែច្បាស់អំពីដំណើរការនៃការអភិវឌ្ឍការចិញ្ចឹមសត្វ ក៏ដូចជាយល់ដឹងអំពីបញ្ហាប្រឈម និងដំណោះស្រាយល្អៗ ដែលមាននៅក្នុងចិញ្ចឹមសត្វផងដែរ។យើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវមួយនេះ និងអាចចូលរួមចំណែកក្នុងការ ជួយសម្រួលដល់ស្ថានភាពនៅក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធនឹងការចិញ្ចឹមសត្វ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ ទាំងឡាយផងដែរ។ យ៉ាងណាមិញ ទោះបីជាក្រុមយើងខ្ញុំ បានព្យាយាមអស់ពីសមត្ថភាពទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលា ដើម្បីទទួលបានសមិទ្ធផលមួយនេះឡើងឱ្យបានល្អយ៉ាងណាក៏ដោយ ក៏គង់តែមិន អាចចៀសផុតពីកំហុសឆ្គងទាំងអក្ខរាវិរុទ្ធ ខ្លឹមសារ និងកំហុសឆ្គងផ្សេងៗដោយអចេតនា ដូច្នេះយើងខ្ញុំទាំងអស់គ្នា សូមធ្វើកាអភ័យទោសទុកជាមុនដោយអនុគ្រោះនិង រងចាំទទួលការនូវផ្តល់មតិយោបល់ក្នុងន័យរិះគន់ដើម្បីស្ថាបនាពីសំណាក់គណៈកម្មការវាយតម្លៃ សាស្រ្តាចារ្យ និស្សិត និង មិត្តអ្នកអានទាំងឡាយ ដោយក្តីសោមនស្ស រីករាយបំផុត ដើម្បីឱ្យសៀវភៅមួយនេះកាន់តែល្អប្រសើរឡើងជាងនេះមួយកម្រិតទៀត។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចំណាយពេលវេលាដ៏មានតម្លៃក្នុងការអានឯកសារនេះ ។ យើងខ្ញុំសូមជូនពរដល់គណៈកម្មការវាយតម្លៃ សាស្រ្តចារ្យ និងក្រុមគ្រួសារ ជួបប្រទះតែសំណាងល្អ ព្រមទាំងពុទ្ធពរទាំងឡាយ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

**ទំព័រទី**

**បញ្ជីអក្សរកាត់**............vi
**បញ្ជីតារាង**............vii
**បញ្ជីក្រាហ្វិក**............viii
**បញ្ជីរូប**............ix
**សេចក្តីផ្តើម**............១
**១. លំនាំបញ្ហា**............១
**២. ចំណោទបញ្ហា**............២
**៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ**............២
**៤. ទំហំនិងដែនកំណត់ស្រាវជ្រាវ**............២
**៥. វិធីសាស្រ្តនៃការស្រាវជ្រាវ**............២
ក. ការប្រមូលទិន្នន័យ............៣
ខ. ការវិភាគទិន្នន័យ............៣
**៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ**............៣
**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**............៤
**ជំពូកទី១**
**សិក្សាទ្រឹស្តីនិងនិយមន័យ**
**១.១. និយមន័យការអភិវឌ្ឍ**............៥
**១.២. ទ្រឹស្តីការអភិវឌ្ឍ**............៦
១.២.១. ទ្រឹស្តីរបស់លោក Rostow............៦
១.២.២. ទ្រឹស្តីរបស់លោក W.Arthurlewis............៧
១.២.៣. ទ្រឹស្តីរបស់លោក Michel.P.Todaro............៨
**១.៣. និយមន័យការចិញ្ចឹមសត្វ**............៨
**១.៤. គោលបំណងនៃការអភិវឌ្ឍ**............៨
**១.៥. កត្តាដែលជម្រុញអោយមានការអភិវឌ្ឍ**............៩

១.៥.១. ធនធានមនុស្ស ..... ៩
១.៥.២. ធនធានធម្មជាតិ ..... ៩
១.៥.៣. មូលធន ..... ៩
១.៥.៤ បច្ចេកវិទ្យា ..... ៩
**១.៦. ឧបសគ្គដែលរារាំងក្នុងការអភិវឌ្ឍ** ..... ១០
១.៦.១. ទស្សនៈផ្គត់ផ្គង់សរុប ..... ១០
១.៦.២. ទស្សនៈតម្រូវការសរុប ..... ១០
១.៦.៣. សំយោគទស្សនៈទាំងពីរ ..... ១០
ក. មូលធន និងផលិតភាពកសិកម្ម ..... ១១
ខ. ការអភិវឌ្ឍធនធានមនុស្ស ..... ១១
**១.៧. ប្រវត្តិកសិកម្ម** ..... ១១
ក. ដំណាក់កាតមិនទាន់មានកសិកម្ម ..... ១១
ខ .ដំណាក់កាលកសិកម្មដោយប្រើកម្លាំងមនុស្ស និងសត្វ ..... ១២
គ. ដំណាក់កាលទំនើបកម្មកសិកម្ម ..... ១២
**១.៨. ប្រវត្តិនៃការចិញ្ចឹមសត្វ** ..... ១៣
ខ.ការចិញ្ចឹមបុសបក្សី ..... ១៤
គ.ការចិញ្ចឹមត្រី ..... ១៤
ឃ. ការចិញ្ចឹមឃ្មុំ ..... ១៤
**១.៩. សារៈសំខាន់ក្នុងវិស័យកសិកម្មតាមរយៈការចិញ្ចឹមសត្វ** ..... ១៥
១.៩.១. តួនាទីរបស់បសុសត្វ ..... ១៥
១.៩.២. សារៈសំខាន់នៃវិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ ..... ១៦
១.៩.៣. ការបិភោគបសុត្វ និងប្រាក់ចំណូល ..... ១៧
**១.១០. និរន្តរ៍ភាពតាមរយៈការចិញ្ចឹមសត្វ** ..... ១៧

## ជំពូកទី ២

## ស្ថានភាពវិស័យកសិកម្មនៅប្រទេសកម្ពុជា

**២.១. ស្ថានភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជា** ..... ១៩
**២.២. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ២០១២-២០២២** ... ២១

២.២.១. ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ............ ២៣
២.២.២. កំណើនផលិតផលក្នុងស្រុក GDP ឆ្នាំ ២០២២-២០២៣ ............ ២៤
**២.៣. គោលនយោបាយនិង យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍក្នុងវិស័យកសិកម្ម** ...... ២៦
២.៣.១. គោលបំណងយុទ្ធសាស្ត្រ ............ ២៦
២.៣.២. គោលដៅយុទ្ធសាស្ត្រ ............ ២៧
២.៣.៣. យុទ្ធសាស្ត្រ និងកម្មវិធីការអភិវឌ្ឍន៍វិស័យកសិកម្ម ............ ២៧
២.៣.៤. យុទ្ធសាស្ត្រចតុកោណ ............ ២៩
**២.៤. តួនាទីរបស់រដ្ឋាភិបាលក្នុងវិស័យកសិកម្ម** ............ ២៩
២.៤.១. តួនាទីរបស់អង្គការនៅក្រៅរដ្ឋាភិបាល ............ ៣០
២.៤.២. តួនាទីរបស់ប្រជាជនកសិករនៅក្នុងវិស័យកសិកម្ម ............ ៣១
ក. ផលិតកម្មអាហារ ............ ៣១
ខ. ការរួមចំណែកសេដ្ឋកិច្ច ............ ៣១
គ. និរន្តរភាព និងការគ្រប់គ្រងបរិស្ថាន ............ ៣១
ឃ. ការទទួលយកការច្នៃប្រឌិត និងបច្ចេកវិទ្យា ............ ៣២
**២.៥. ឱកាសសម្រាប់ការវិនិយោគតាមរយៈវិស័យកសិកម្ម** ............ ៣២
ក. ការកែច្នៃកសិផល និងការបន្ថែមតម្លៃ ............ ៣២
ខ. ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព ............ ៣៣
គ. បច្ចេកវិទ្យាកសិកម្មទំនើប ............ ៣៣
ឃ. ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក ............ ៣៣
ង. ការអភិវឌ្ឍន៍បសុសត្វ និងវារីវប្បកម្ម ............ ៣៤
ច. ខ្សែសង្វាក់ផ្គត់ផ្គង់ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ............ ៣៤
ឆ. សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង ............ ៣៤
ជ. ស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ............ ៣៤
ឈ. ទេសចរណ៍កសិ-ទេសចរណ៍ និងអេកូទេសចរណ៍ ............ ៣៥
ញ. ភាពជាដៃគូសាធារណៈ និងឯកជន (PPPs) ............ ៣៥
**២.៦. ការប្រៀបធៀបផែនផលិតកម្មតាមប្រភេទសត្វ ក្នុងឆ្នាំ ២០១៩-២០២៣** ... ៣៦
២.៦.១. ការប្រៀបធៀបបែបផែនផលិតកម្មសត្វសរុប ............ ៣៦

២.៦.២. ការប្រៀបធៀបផលិតកម្មគោ និងក្របី ........ ៣៩
២.៦.៣. ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក ........ ៤២
២.៦.៤. ការប្រៀបធៀបបែបផែនផលិតកម្មបក្សី ........ ៤៥
២.៦.៥. ការប្រៀបធៀបបែបផែនផលវារីវប្បកម្ម ........ ៤៨
**២.៧. តម្រូវការសត្វ និងសាច់សត្វ** ........ ៤៨
**២.៨. ការអភិវឌ្ឍនៃវិស័យកសិកម្មតាមរយៈការចិញ្ចឹមសត្វ** ........ ៥១
២.៨.១. ការជំរុញសុខភាពសត្វ ........ ៥១
២.៨.២. ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល ........ ៥២
២.៨.៣. កម្មវិធីកែលម្អពូជ ........ ៥៣
២.៨.៤. អំពីចំណីសត្វ ........ ៥៤
២.៨.៥. ការគ្រប់គ្រងកាកសំណល់សត្វ ........ ៥៥
**២.៩. អត្ថប្រយោជន៍បានពីផលិតផលសាច់សត្វ** ........ ៥៦
២.៩.១. ផលិតផលសត្វគោ ........ ៥៦
២.៩.២. ផលិតផលសត្វជ្រូក ........ ៥៧
២.៩.៣. ផលិតផលសត្វមាន់ ........ ៥៧
២.៩.៤. ផលិតផលសត្វទា ........ ៥៧

**ជំពូកទី ៣**

**ការព្យាករណ៍នៅក្នុងវិស័យចិញ្ចឹមសត្វ**

**៣.១. ការនាំចេញនាំចូលផលិតកម្មសត្វ ក្នុងឆ្នាំ ២០២២ & ២០២៣** ........ ៥៨
**៣.២. ការវិភាគទៅលើការចិញ្ចឹមសត្វនាពេលបច្ចុប្បន្ន** ........ ៥៩
**៣.៣. ការវិភាគទៅលើការចិញ្ចឹមសត្វនាពេលអនាគត** ........ ៥៩
**៣.៤. ការព្យាករណ៍ការប្រៀបធៀបបែបផែនផលិតកម្មសត្វសរុប ក្នុងឆ្នាំ ២០២៣-២០២៦** ........ ៦១
៣.៤.១ ការព្យាករណ៍ទៅលើបែបផែនផលិតកម្មសត្វសរុប ពីឆ្នាំ២០២៣-២០២៦ ........ ៦១
៣.៤.២ ការព្យាករណ៍ទៅលើបែបផែនផលិតកម្មសត្វគោ-ក្របី ពីឆ្នាំ២០២៣-២០២៦ ........ ៦២
៣.៤.៣. ការព្យាករណ៍ទៅលើបែបផែនផលិតកម្មសត្វជ្រូក ពីឆ្នាំ២០២៣-២០២៦ ........ ៦៣
៣.៤.៤. ការព្យាករណ៍ទៅលើបែបផែនផលិតកម្មសត្វបក្សី ពីឆ្នាំ២០២៣-២០២៦ ........ ៦៤

៣.៤.៥ ការព្យាករណ៍ទៅលើបែបផែនផលវារីវប្បកម្ម ពីឆ្នាំ២០២៣-២០២៦ ........................ ៦៥

## ជំពូកទី ៤

## បញ្ហាប្រឈមនិងដំណោះស្រាយ

**៤.១. បញ្ហាប្រឈមក្នុងវិស័យកសិកម្មឆ្នាំ២០២០ និង ២០២៣** .................................. ៦៧
៤.១.១ បញ្ហាប្រឈមក្នុងវិស័យកសិកម្មក្នុងការចិញ្ចឹមសត្វក្នុងឆ្នាំ២០២០ ............................ ៦៨
៤.១.២ បញ្ហាប្រឈមក្នុងវិស័យកសិកម្មក្នុងឆ្នាំ២០២១ ........................................................ ៦៩
៤.១.៣. បញ្ហាប្រឈមក្នុងវិស័យកសិកម្មក្នុងឆ្នាំ២០២២ ...................................................... ៦៩
៤.១.៤. បញ្ហាប្រឈមក្នុងវិស័យកសិកម្មក្នុងឆ្នាំ២០២៣ ...................................................... ៧០
**៤.២. ដំណោះស្រាយនានាដែលទាក់ទងទៅនឹងបញ្ហាប្រឈម** .................................. ៧០
**៤.៣. បញ្ហាប្រឈម នៅលើការចិញ្ចឹមសត្វនីមួយៗ** ........................................................ ៧១
ក.បញ្ហាប្រឈមលើការចិញ្ចឹមសត្វគោ ក្របី ........................................................................ ៧១
ខ. បញ្ហាប្រឈមលើការចិញ្ចឹមសត្វជ្រូក ............................................................................ ៧២
គ. បញ្ហាប្រឈមលើការចិញ្ចឹមសត្វមាន់ ទា .......................................................................... ៧៣
ឃ. បញ្ហាប្រឈមលើវារីវប្បកម្ម ........................................................................................... ៧៥
**៤.៤. ដំណោះស្រាយលើការចិញ្ចឹមសត្វនីមួយៗ** ........................................................ ៧៤
ក. ដំណោះស្រាយលើការចិញ្ចឹមសត្វគោ និងក្របី ..................................................................... ៧៥
ខ. ដំណោះស្រាយលើការចិញ្ចឹមសត្វជ្រូក ............................................................................. ៧៥
គ.ដំណោះស្រាយលើការចិញ្ចឹមសត្វមាន់ ទា .......................................................................... ៧៦
ឃ. ដំណោះស្រាយរបស់វារីវប្បកម្ម ....................................................................................... ៧៩
**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** ........................................................................ ៧៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| ពាក្យអក្សរកាត់ | | ការពន្យល់ |
|---|---|---|
| គ.ម² | ៖ | គីឡូម៉ែត្រការ៉េ |
| គ.ស | ៖ | គ្រឹស្តសករាជ |
| % | ៖ | ភាគរយ |
| ល.រ | ៖ | លេខរៀង |
| ផសស | ៖ | ផលិតផលក្នុងស្រុកសរុប |
| GDP | ៖ | Gross Domestic Product |
| R&D | ៖ | Research and development |
| PPPs | ៖ | Public-Private Partnerships |
| IMF | ៖ | International Monetary Fund |

# បញ្ជីតារាង

តារាងទី២.១  បង្ហាញអំពីកសិដ្ឋានចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មឆ្នាំ ២០២២-២០២៣
តារាងទី២.២  បង្ហាញអំពីស្ថិតិកសិដ្ឋានចិញ្ចឹមសត្វតាមចំណាត់ថ្នាក់ខ្នាតប្រចាំឆ្នាំ ២០២៣
តារាងទី២.៣  បង្ហាញអំពីកសិដ្ឋានចិញ្ចឹមគោ-ក្របី លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣
តារាងទី២.៤  បង្ហាញអំពីកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣
តារាងទី២.៥  បង្ហាញអំពីកសិដ្ឋានចិញ្ចឹមបក្សីលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី២.១  បង្ហាញពីការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិឆ្នាំ ២០១២-២០២២

ក្រាហ្វិកទី២.២  បង្ហាញអំពីតម្លៃបន្ថែមសរុបនៃវិស័យកសិកម្មក្នុងឆ្នាំ ២០១២-២០២១

ក្រាហ្វិកទី២.៣   ការវាយតម្លៃ និងព្យាករកំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២២-២០២៣

ក្រាហ្វិកទី២.៤   បង្ហាញអំពីការប្រៀបធៀបបែបផែនផលិតកម្មសត្វសរុបពីឆ្នាំ ២០១៩-២០២៣

ក្រាហ្វិកទី២.៥   បង្ហាញអំពីការប្រៀបធៀបអត្រានៃបែបផែនផលិតកម្មសត្វសរុបពីឆ្នាំ ២០១៩-២០២៣

ក្រាហ្វិកទី២.៦   បង្ហាញអំពីកសិដ្ឋានចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម ពីឆ្នាំ ២០២២-២០២៣

ក្រាហ្វិកទី២.៧   បង្ហាញអំពីការប្រៀបធៀបបែបផែនផលិតកម្មគោ-ក្របី ពីឆ្នាំ២០១៩-២០២៣

ក្រាហ្វិកទី២.៨   បង្ហាញអំពីការប្រៀបធៀបអត្រានៃបែបផែនផលិតកម្មគោ-ក្របី ពីឆ្នាំ២០១៩-២០២៣

ក្រាហ្វិកទី២.៩   បង្ហាញអំពីកសិដ្ឋានចិញ្ចឹមគោ-ក្របី លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣

ក្រាហ្វិកទី២.១០ បង្ហាញអំពីការប្រៀបធៀបបែបផែនផលិតកម្មជ្រូក ពីឆ្នាំ ២០១៩-២០២៣

ក្រាហ្វិកទី២.១១ បង្ហាញអំពីការប្រៀបធៀបអត្រានៃបែបផែនផលិតកម្មជ្រូក ពីឆ្នាំ ២០១៩-២០២៣

ក្រាហ្វិកទី២.១២ បង្ហាញអំពីកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣

ក្រាហ្វិកទី២.១៣ បង្ហាញអំពីការប្រៀបធៀបបែបផែនផលិតកម្មបក្សី ពីឆ្នាំ ២០១៩-២០២៣

ក្រាហ្វិកទី ២.១៤ បង្ហាញអំពីការប្រៀបធៀបអត្រានៃបែបផែនផលិតកម្មបក្សី ពីឆ្នាំ ២០១៩-២០២៣

ក្រាហ្វិកទី២.១៥ បង្ហាញអំពីកសិដ្ឋានចិញ្ចឹមបក្សីលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣

ក្រាហ្វិកទី២.១៦ បង្ហាញពីផលនេសាទទឹកសាប ទឹកសមុទ្រ និង វារីវប្បកម្ម (តោន)

ក្រាហ្វិកទី២.១៧បង្ហាញអំពីការបរិភោគក្នុងមនុស្សម្នាក់ក្នុង១ឆ្នាំ

ក្រាហ្វិកទី២.១៨ បង្ហាញអំពីតម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាតក្នុងរយៈពេល៣០ឆ្នាំ (១៩៩៣-២០២៣)

ក្រាហ្វិកទី២.១៩ បង្ហាញអំពីអត្រានៃតម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាតក្នុងរយៈពេល៣០ឆ្នាំ (១៩៩៣-២០២៣)

ក្រាហ្វិកទី៣.១  ការព្យាករណ៍ការប្រៀបធៀបបែបផែនផលិតកម្មសត្វសរុប

ក្រាហ្វិកទី៣.២ ការព្យាករណ៍ការប្រៀបធៀបបែបផែនផលិតកម្មសត្វគោ-ក្របី

ក្រាហ្វិកទី៣.៣ ការព្យាករណ៍ការប្រៀបធៀបបែបផែនផលិតកម្មសត្វជ្រូក

ក្រាហ្វិកទី៣.៤ ការព្យាករណ៍ការប្រៀបធៀបបែបផែនផលិតកម្មសត្វបក្សី

ក្រាហ្វិកទី៣.៥ ការព្យាករណ៍បែបផែនផលនេសាទទឹកសាប ទឹកសមុទ្រ និង វារីវប្បកម្ម (តោន)

# បញ្ជីរូប

ដ្យាក្រាមទី១.១ ទស្សនៈផ្គត់ផ្គង់សរុប

ដ្យាក្រាមទី១.២ ទស្សនៈតម្រូវការសរុប

ដ្យាក្រាមទី ១.៣ សំយោគទស្សនៈតម្រូវការសរុប និងផ្គត់ផ្គង់សរុប

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសស្ថិតនៅប៉ែកអាស៊ីអាគ្នេយ៍ដែលមានសេដ្ឋកិច្ចកសិកម្មលើសលុប យើងឃើញថាមានការបោះជំហានយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ការចិញ្ចឹមសត្វក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ។ តាមរយៈប្រវត្តិសាស្ត្រ ការចិញ្ចឹមសត្វគឺជាផ្នែកមួយដ៏សំខាន់នៃកសិកម្មកម្ពុជា ដែលរួមចំណែកដល់ការចិញ្ចឹមជីវិតរបស់គ្រួសារនៅតាមជនបទជាច្រើន និងដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀងសម្រាប់ប្រជាជន។ វិស័យនេះពាក់ព័ន្ធនឹងការចិញ្ចឹមគោ ក្របី ជ្រូក បសុបក្សី និងទា ដែលជាមូលដ្ឋានគ្រឹះសម្រាប់ក្របខណ្ឌកសិកម្មរបស់ប្រទេសជាតិ។

រដ្ឋាភិបាលកម្ពុជា រួមជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានអនុវត្តគំនិតផ្តួចផ្តើមជាច្រើន ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វប្រកបដោយនិរន្តរភាព។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមានការកែលម្អសេវាសុខភាពសត្វ ការផ្តល់ការបណ្តុះបណ្តាល និងធនធានដល់កសិករ និងការលើកទឹកចិត្តដល់ការទទួលយកបច្ចេកទេសកសិកម្មទំនើប។ ការអភិវឌ្ឍនៃការចិញ្ចឹមសត្វក៏ត្រូវបានគាំទ្រដោយគោលនយោបាយដែលមានគោលបំណងលើកកម្ពស់ផលិតភាពកសិកម្ម និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ដូចនេះបញ្ជាក់អោយបានឃើញថាមានប្រជាជននៅកម្ពុជាមានកម្រិតជីវភាពមិនទាន់ខ្ពស់នៅឡើយ។ សម្រាប់ពេលបច្ចុប្បន្នការចិញ្ចឹមសត្វនៅប្រទេសកម្ពុជាមានកម្រិតនូវទាបនូវឡើយហើយមានជាលក្ខណៈគ្រួសារ និងខ្វះបច្ចេកទេសជាច្រើន។ ការធ្វើកសិកម្មនៅកម្ពុជាភាគច្រើនត្រូវបានគេប្រើសត្វគោ និងក្របីជាកម្លាំងអូសទាញ ។រីឯសត្វគោវិញត្រូវបានគេប្រើសម្រាប់ញួរ រាស់ដីសម្រាប់រដូវវស្សាដើម្បីជួយសម្រួលកម្លាំងកសិករ។

## ១. លំនាំបញ្ហា

ប្រទេសជាប្រទេសដែលមានប្រជាជនប្រមាណ ១៧លាននាក់។ ប្រទេសកម្ពុជា ជាប្រទេសមួយដែលពឹងផ្អែកទៅលើកសិកម្មជាសំខាន់ពីព្រោះប្រជាជានប្រមាណ ៨០%ទៅ៨៥%គឺជាកសិករ ហើយកសិកម្មបានផ្តល់ ៥០%នៃផលិតផលជាតិសរុប។ នៅក្នុងនោះផងដែរមានផលិតផលកសិកម្មដូចជា ដំណាំរួមផ្សំ៦៣% ការចិញ្ចឹមសត្វ២៤% ការនេសាទ១០% និងព្រៃឈើ៣%។នៅក្នុងវិស័យកសិកម្មតាមរយៈការចិញ្ចឹមសត្វផងដែរមានប្រជាជននៅតាមជនបទភាគច្រើនបានពឹងផ្អែលលើវិស័យនេះសម្រាប់ជីវភាពរស់នៅ។ ការចិញ្ចឹមសត្វ បានធ្វើអោយប្រជាជននៅតាមជនបទកាត់បន្ថយការចំណាយមួយចំនួននៅក្នុងគ្រួសារ។ បន្ថែមពីនេះទៅទៀតការចិញ្ចឹមសត្វមានតួនាទីយ៉ាងសំខាន់ជាប្រភពចំណូលរបស់ប្រជាជននៅតាមជនបទផងដែរ ដែលពួកគាត់អាចប្រើប្រាស់វិធីក្នុងការចិញ្ចឹមសត្វនេះយកទៅប្រកបមុខរបររបស់ពួកគាត់ដូចជា ការចិញ្ចឹមគោ មាន់ ទា យកទៅលក់ផងដែរ។ ដោយសង្កេតឃើញថាការចិញ្ចឹមសត្វនៅតាមជនបទរបស់ប្រជាជននៅមានកម្រិតទាបនៅឡើយ ដោយពួកគាត់បានចិញ្ចឹមតាមលក្ខណៈគ្រួសារតូចតាច និងមានកម្រិតទាប។ មិនត្រឹមតែប៉ុណ្ណោះក្នុងការចិញ្ចឹម

សត្វនៅតាមជនបទដែលជាលក្ខណៈគ្រួសារ បានជួបនៅបញ្ហាមួយចំនួនដូចជា ជួបនូវគ្រោះទឹកជំនន់ ជួបនូវបញ្ហាការឆ្លងជម្ងឺផ្សេងៗ ខ្វះនូវបច្ចេកទេសក្នុងការចិញ្ចឹម ខ្វះចំណេះដឹងក្នុងការថែទាំផ្សេងៗ។

## ២. ចំណោទបញ្ហា

សម្រាប់ក្នុងការស្រាវជ្រាវនេះបានធ្វើអោយយើងបានយល់និងដឹងយ៉ាងច្បាស់អំពីនៅក្នុងវិស័យកសិកម្មតាមរយៈការចិញ្ចឹមសត្វតាមរយៈវិស័យកសិកម្ម ដែលធ្វើអោយដឹងអំពីបញ្ហាប្រឈមនានា អត្ថប្រយោជន៍ និងតួនាទីក្នុងការចិញ្ចឹមសត្វចំពោះគ្រួសាររបស់ប្រជាជន និងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាទាំងមូល។ តាមរយៈការស្រាវជ្រាវមួយនេះបានធ្វើអោយអ្នកស្រាវជ្រាវ និងអ្នកអានបានយល់ដឹងនូវៈ

- តើកសិកម្មនៅប្រទេសកម្ពុជាមានស្ថានភាពដូចម្ដេច?
- តើមានបញ្ហាអ្វីខ្លះក្នុងការចិញ្ចឹមសត្វនៅប្រទេសកម្ពុជា?
- តើការចិញ្ចឹមសត្វមានអត្ថប្រយោជន៏អ្វីខ្លះដល់ប្រជាជននិង សេដ្ឋកិច្ចនៅប្រទេសកម្ពុជា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

សម្រាប់ការស្រាវជ្រាវនេះមានគោលបំណងចង់សិក្សាអោយស៊ីជម្រៅ និងរកវិធីសាស្ត្រដែលធ្វើអោយការចិញ្ចឹមសត្វនៅប្រទេសកម្ពុជាមានការរីកចម្រើន និងមានប្រសិទ្ធភាពជាងមុន។ មិនតែប៉ុណ្ណោះក៏បានសិក្សាអំពីអត្ថប្រយោជន៏ ផលប៉ះពាល់ ចំពោះសេដ្ឋកិច្ចលក្ខណៈគ្រួសារ និងសេដ្ឋកិច្ចនៅប្រទេសកម្ពុជាផងដែរ។

## ៤. ទំហំនិងដែនកំណត់ស្រាវជ្រាវ

ការសិក្សានេះ ផ្ដោតសំខាន់ទៅលើការចិញ្ចឹមសត្វដូចជាៈ សត្វគោ សត្វក្របី សត្វមាន់ សត្វទា សត្វជ្រូក ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាផ្ទាល់តែម្ដង។ មិនត្រឹមតែប៉ុណ្ណោះសិក្សាអំពីបញ្ហាប្រឈមនានា ចំណីអាហាររបស់សត្វទាំងនេះ។ ម្យ៉ាងវិញទៀតសិក្សាអំពីទិន្នន័យការប្រៀបធៀបផលិតកម្មសត្វដែលមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងពេលបច្ចុប្បន្ននិងអនាគត ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាផងដែរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការជ្រាវជ្រាវទៅលើប្រធានបទនេះ យើងខ្ញុំបានពឹងផ្អែកទៅលើទិន្នន័យចំនួនពីរ គឺ ទិន្នន័យបន្ទាប់បន្សំ ( Secondary Data )។ ទិន្នន័យបន្ទាប់បន្សំ ( Secondary Data ) គឺជាប្រភេទទិន្នន័យស្រាវជ្រាវដែលប្រមូលបានពីការស្រាវជ្រាវតាមរយៈឯកសារនានា និងសៀវភៅដែលទាក់ទង ដើម្បីធ្វើអោយបាយការណ៍នេះអោយបានកាន់តែប្រសើរយើងក៏បានស្រាវជ្រាវលើទិន្នន័យដែលមានស្រាប់ដូចជា សៀវភៅ ឯកសារនានាដែលពាក់ព័ន្ធ និងរបាយការណ៍ដែរដែលបានចេញផ្សាយនានាដែលអាចរកបាន តាមរយៈគេហទំព័ររបស់ធនាគាពិភពលោកប្រចាំនៅកម្ពុជា ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ព្រមទាំងឯកសារតាមរយៈគេហទំព័រដែលមានប្រភពច្បាស់លាស់។

**ក. ការប្រមូលទិន្នន័យ**

នៅក្នុងសារណានេះផងដែរ គឺបាននាំយកនូវទិន្នន័យដែលទាក់ទងនឹងប្រមូលមកពីឯកសារនានា ដែលបានមកពី៖

- ឯកសាររបាយការណ៍បូកសរុបការងារប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម
- សៀវភៅសារណា និងរបាយការណ៍បញ្ចប់ការសិក្សា នៅក្នុងសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៩-២០២៣
- របាយការណ៍បូកសរុបការងារសុខភាពសត្វ និងផលិតកម្មប្រចាំឆ្នាំ ២០១៩ និងលើកទិសដៅការងារឆ្នាំ ២០២០)
- ឯកសារនានាដែលបានមកពីប្រព័ន្ធអ៊ីនធឺណេត។ល។

**ខ. ការវិភាគទិន្នន័យ**

បន្ទាប់ពីបានប្រមូលទិន្នន័យ និងព័ត៌មានរួចមក យើងបានធ្វើការជ្រើសរើសព័ត៌មានណាដែលសំខាន់ៗ និងមានប្រយោជន៍សម្រាប់បង្កើតជាវិធីសាស្ត្រសម្រាប់ការព្យាករណ៍ទៅលើបែបផែនផលិតកម្មវិស័យកសិកម្ម តាមរយៈការចិញ្ចឹមសត្វនៅឆ្នាំបន្តបន្ទាប់នៅក្នុងប្រព័ន្ធ Excel ដើម្បីជាជំនួយក្នុងការវិភាគទិន្នន័យទាំងអស់អោយមានប្រសិទ្ធភាព និងមានសុក្រិតភាព។ មិនតែប៉ុណ្ណោះបានបង្ហាញជាតារាងក្រោយពីព្យាករណ៍ទិន្នន័យរួច ដើម្បីងាយស្រួលក្នុងការបកស្រាយនិងងាយយល់។

## ៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវប្រធានបទនេះ៖

- ការលើកកម្ពស់ផលិតភាពបសុសត្វ
- សន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ការកែលម្អសុខភាពសត្វ និងសុខុមាលភាព
- ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រតាមរយៈការចិញ្ចឹមសត្វ
- ការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុរបស់សត្វ
- កិច្ចសហប្រតិបត្តិការអន្តរជាតិ និងពាណិជ្ជកម្ម
- ការកសាងសមត្ថភាព និងការអប់រំដល់ប្រជាកសិករ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានចែកជា ៤ជំពូក៖

- **សេចក្ដីផ្ដើម៖** លំនាំបញ្ហា ចំណោទបញ្ហា និងចំណូលបញ្ហា ជាចំណុចចាប់ផ្ដើមនៃប្រធានបទដើម្បីអោយអ្នកអានងាយស្រួលយល់ដែលសិក្សាអំពីស្ថានភាពទូទៅ និងមូលហេតុនៃការសិក្សា ទំហំ និងដែនកំណត់ ដែលផ្ដោតសំខាន់ទៅលើការអភិវឌ្ឍវិស័យកសិកម្មតាមរយៈការចិញ្ចឹមសត្វនៅប្រទេសកម្ពុជា។
- **ជំពូកទី១៖** ការសិក្សាទ្រឹស្ដីនិងនិយមន័យដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដែលបង្ហាញអំពីទ្រឹស្ដីនិងនិយមន័យរបស់អ្នកប្រាជ្ញមួយចំនួនលើកមកបញ្ជាក់អោយបានឃើញនិងងាយស្រួលយល់ ម្យ៉ាងវិញទៀតបង្ហាញអំពីប្រវិត្តនៃការធ្វើកសិកម្ម គោលបំណងនៃការធ្វើកសិកម្ម កត្តាជម្រុញអោយមានការអភិវឌ្ឍ ហើយនិងឧបសគ្គជារាំងនៅក្នុងការអភិវឌ្ឍថែមទៀតផង។
- **ជំពូកទី២៖** ស្ថានភាពវិស័យកសិកម្មនៅប្រទេសកម្ពុជា និងការប្រៀបធៀបបែបផែនផលិតកម្មសត្វនៅប្រទេសកម្ពុជានៅឆ្នាំ២០១៩ទៅដល់ឆ្នាំ២០២៣ មិនតែប៉ុណ្ណោះបានបង្ហាញពីការអភិវឌ្ឍនៃវិស័យកសិកម្មតាមរយៈការជម្រុញសុខភាពសត្វ ការកែលម្អពូជសត្វ ចំណីសត្វ និងការគ្រប់គ្រងកាកសំណល់សត្វជាដើម។ មិនតែប៉ុណ្ណោះបានបង្ហាញពីតួនាទីរបស់បសុសត្វ និងអត្ថប្រយោជន៍អំពីសាច់សត្វទាក់ទងទៅនឹងការកាត់បន្ថយភាពក្រីក្រ។ ម្យ៉ាងវិញទៀតបង្ហាញពីគោលនយោបាយនិង យុទ្ធសាស្ត្រនានាសម្រាប់ការអភិវឌ្ឍក្នុងវិស័យកសិកម្មផងដែរ។
- **ជំពូកទី៣៖** ការព្យាករណ៍នៅក្នុងវិស័យកសិកម្ម ក្នុងជំពូកនេះ បង្ហាញអំពី ការនាំចេញនាំចូល ការវិភាគលើការចិញ្ចឹមសត្វនាពេលបច្ចុប្បន្ននិង អនាគត និង ការព្យាករណ៍ផលិតផលសត្វសរុប។
- **ជំពូកទី៤៖** ការសិក្សាលើបញ្ហាប្រឈមនិងដំណោះស្រាយ ក្នុងជំពូកនេះ បកស្រាយអំពីទិដ្ឋភាពសំខាន់ៗដែលជាបញ្ហាប្រឈមចំពោះវិស័យកសិកម្មផ្នែកចិញ្ចឹមសត្វ និង សិក្សារែកញែកថាតើត្រូវរក ដំណោះស្រាយបែបណា ដែលសមស្របទៅនឹងបញ្ហាទាំងអស់នោះ។

# ជំពូកទី១

# សិក្សាទ្រឹស្តីនិងនិយមន័យ

# ជំពូកទី១
# សិក្សាទ្រឹស្តីនិងនិយមន័យ

## ១.១. និយមន័យការអភិវឌ្ឍ

- ការអភិវឌ្ឍ គឺជាការធ្វើអោយប្រសើរជាងមុន។
- ការអភិវឌ្ឍ គឺជាការបង្កើតពីគ្មានអោយមាន ហើយពីមានអោយប្រសើរជាងមុន។
- ការអភិវឌ្ឍ គឺជាដំណើរការដែលនរណាម្នាក់ ឬអ្វីមួយលូតលាស់ ផ្លាស់ប្តូរទៅជាកាន់តែជឿនលឿនប្រសើរឡើង។
- ការអភិវឌ្ឍ គឺជាដំណើរការនៃការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ និងស្ថាប័ន ដែលបង្កលក្ខណៈងាយស្រួល ឬអំណោយផលដល់ការធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន និងធ្វើឲ្យកំណើនសេដ្ឋកិច្ចបន្តបានយូរ ឬអាចនិយាយបានម្យ៉ាងទៀតថា ការអភិវឌ្ឍ ជាការបង្កលក្ខខណ្ឌឲ្យសេដ្ឋកិច្ចមានចីរភាព។

ក្នុងន័យសេដ្ឋកិច្ច ការអភិវឌ្ឍ គឺទាក់ទងទៅនឹងការកែលំអនៅក្នុងស្ថានភាពសេដ្ឋកិច្ចរបស់មនុស្ស គុណភាពរស់នៅល្អប្រសើរជាងមុន អត្រាកំណើនចំណូលក្នុងពលរដ្ឋម្នាក់ៗ ឬ ផលិតផលជាតិក្នុងពលរដ្ឋម្នាក់ៗ ក៏ដូចជានៅក្នុងប្រទេសទាំងមូល។ ការអភិវឌ្ឍត្រូវបានលើកឡើងក្នុងទម្រង់នៃការកាត់បន្ថយនិងលុបបំបាត់នូវភាពក្រីក្រ វិសាលភាពនិងនិកម្មភាពជាដើម។

ការអភិវឌ្ឍអាចស្តែងចេញតាមមាត្រដ្ឋានចំនួនគឺៈ

**១. មាត្រដ្ឋានសេដ្ឋកិច្ចៈ** ការអភិវឌ្ឍ គឺជាកំណើនសេដ្ឋកិច្ចដែលទាក់ទងនឹងការកែលម្អផ្នែកហេដ្ឋរចនាសម្ព័ន្ធ ដូចជាការផ្គត់ផ្គង់ទឹក ប្រព័ន្ធថាមពល ការកែលម្អផ្នែកវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតដែលធ្វើយ៉ាងណាអោយប្រសើរជាងមុន។

**២. មាត្រដ្ឋានសង្គមៈ** ការអភិវឌ្ឍ គឺជាការកែប្រែផ្នែកសង្គមកិច្ចដូចជា សមធម៌ និងយុត្តិធម៌តាមរយៈការកាត់បន្ថយភាពក្រីក្រ និងការធ្វើអោយមានភាពយេនឌ័រចំពោះស្ត្រីនិងបុរស ម្យ៉ាងវិញទៀតធ្វើអោយកុមារមានសិទ្ធក្នុងការរស់នៅក្នុងសង្គម។

**៣. មាត្រដ្ឋាននយោបាយៈ** ការអភិវឌ្ឍ គឺត្រូវស្ថិតនៅក្នុងការធ្វើយ៉ាងណាអោយមានច្បាប់ និងគោរពទៅតាមច្បាប់ក្នុងប្រទេសដែលរស់នៅ។

**៤. មាត្រដ្ឋានបរិស្ថានៈ** ការអភិវឌ្ឍ គឺត្រូវស្ថិតក្នុងការធ្វើយ៉ាងណាអោយមានការរីកចម្រើនចំពោះបរិស្ថានដែលយើងរស់នៅ និងធ្វើអោយធម្មជាតិមានពភាពស្ថិតស្ថេរ និងកាត់បន្ថយការបំពុលចំពោះបរិស្ថាន។

**៥. មាត្រដ្ឋានធនធានមនុស្ស៖** ការអភិវឌ្ឍ គឺត្រូវបានផ្សារភ្ជាប់ទៅនឹងការបង្កើននូវកម្រិតចំណេះដឹងរបស់មនុស្ស និងធ្វើយ៉ាងណាអោយបច្ចេកវិទ្យាដែលរស់នៅមានភាពរីកចម្រើន ផ្តល់ការអប់រំសម្រាប់ប្រជាជនទូទៅ និងការផ្តល់នូវសេវាកម្មសុខភាពបានត្រឹមត្រូវ។[1]

## ១.២. ទ្រឹស្តីការអភិវឌ្ឍ

ទ្រឹស្តីអភិវឌ្ឍ គឺជាពាក្យមួយដែលមានន័យយ៉ាងទូលំទូលាយ ហើយត្រូវបានអ្នកប្រាជ្ញអោយនិយមន័យទៅតាមសម័យកាលនិមួយៗ និងទៅតាមទស្សនៈរបស់អ្នកប្រាជ្ញរៀងខ្លួន។ ខាងក្រោមនេះជាទ្រឹស្តីរបស់អ្នកប្រាជ្ញសម្រាប់ការបកស្រាយអំពីនិយមន័យពាក្យ អភិវឌ្ឍន៍ ៖

### ១.២.១ ទ្រឹស្តីរបស់លោក Rostow

លោក Rostow បានអោយនិយមន័យចំពោះការអភិវឌ្ឍ ទៅជាពាក្យ "ដំណាក់កាលនៃកំណើនសេដ្ឋកិច្ច" ។ នៅឆ្នាំ ១៩៦០ លោកបានបង្ហាញអំពីជំហានចំនួនប្រាំដែលប្រទេសទាំងអស់ត្រូវតែឆ្លងកាត់ដើម្បីក្លាយជាការអភិវឌ្ឍន៍ ដែលក្នុងនោះមានដូចជា៖

- **សង្គមប្រពៃណី**

នៅក្នុងដំណាក់កាលនេះត្រូវបានកំណត់ពីប្រភពចំណូលដែលសេដ្ឋកិច្ចទ្រទ្រង់កសិកម្មមានកម្លាំងពលកម្មខ្លាំង ប៉ុន្តែកម្រិតនៃការជួញដូរទាប និងប្រជាជនមួយចំនួនមិនទាន់បានយល់ច្បាស់ពីទស្សនៈវិស័យវិទ្យាសាស្ត្រលើពិភពលោក និងបច្ចេកវិទ្យាទំនើប។ ហេតុនេះហើយទើបធ្វើអោយមានការកែប្រែសង្គម និងទំនាក់ទំនងផលិតកម្មស្មើសូន្យ មានការប្រកាន់នានុក្រមខ្លាំងនៅក្នុងទំនាក់ទំនងសង្គម ពោលគឺប្រទេសមានការរីកចម្រើនតិចតួចបំផុត។

- **សង្គមស្ថិតក្នុងចំណុចរបត់ទៅរកការអភិវឌ្ឍ**

នៅក្នុងដំណាក់កាលនេះសង្គមបានចាប់ផ្តើមអភិវឌ្ឍផលិតកម្មជាតិ និងអន្តរជាតិកាន់តែច្រើន ដែលបានធ្វើអោយមានការកើនឡើងក្នុងការវិនិយោគហើយនាំអោយមានផលចំណេញដល់សង្គម។ ការផ្លាស់ប្តូរនេះបានធ្វើអោយមានភាពប្រសើរឡើងផ្នែកបច្ចេកវិទ្យា និងការធ្វើឲ្យប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធលើអចលនវត្ថុព្រមទាំងធ្វើឲ្យកើនឡើង សន្សំ និងការវិនិយោគ ជាប្រទេសដែលស្ថិតនៅចន្លោះអន្តរកាលនៃការអភិវឌ្ឍ។

[1] សារណាបញ្ចប់ការសិក្សា (ការអភិវឌ្ឍជីវភាពគ្រួសារតាមរយៈការចិញ្ចឹមទា) និសិត្ស៖ *ស៊ឹម សុខា និង ងន គឹមសៀង*, ទំព័រទី ៥

- **ការចាកចេញដើម្បីចាប់ផ្ដើមអភិវឌ្ឍន៍**

Rostow បាននិយាយថាដំណាក់កាលនេះថាជារយៈពេលខ្លីនៃកំណើនដែលពឹងផ្អែកខ្លាំង ទៅលើឧស្សាហូបនីយកម្មដែលកំពុងចាប់ផ្ដើមកើតឡើង ហើយកម្មករ និងស្ថាប័នបានប្រមូលផ្ដុំជុំវិញឧស្សាហកម្មថ្មី ដើម្បីរក្សាអោយបាននូវស្ថេរភាពសេដ្ឋកិច្ច។

- **ដំណាក់កាលចាស់ទុំ**

នៅដំណាក់កាលនេះកើតឡើងនិងបានរីកដុះដាលគ្រប់ទិសទីពាសពេញផ្ទៃប្រទេស ដោយសារស្តង់ដារនៃការរស់នៅកើនឡើង ការប្រើប្រាស់បច្ចេកវិទ្យាកើនឡើង ហើយសេដ្ឋកិច្ចជាតិរីកចម្រើន និងធ្វើពិពិធកម្ម។

- **ដំណាក់កាលនៃបម្រើបម្រាស់ទ្រង់ទ្រាយធំ**

នៅដំណាក់កាលនេះការអភិវឌ្ឍបានធ្វើអោយប្រទេសជាតិកាន់តែទំនើប សម្បូរបែប ផលិតកម្មទំនិញ និងសេវាកម្មបានដំណើរការយ៉ាងរលូន។ ដោយសារតែចំណូលរបស់ប្រជាជនមានការកើនឡើង ទើបជាហេតុធ្វើអោយប្រជាជនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់នូវទំនិញ និងសម្ភារៈតាមដែលពួកគេត្រូវការ ទាំងនេះបានបញ្ជាក់អោយឃើញថាកម្រិតជីវភាពរបស់ប្រជាជនមានការកើនឡើងទ្រង់ទ្រាយធំ។[2]

### **១.២.២. ទ្រឹស្ដីរបស់លោក** W.Arthurlewis

ទ្រឹស្ដីលោក Lewis បានពន្យល់ផងដែរថា កំណើនសេដ្ឋកិច្ចបានចាប់ផ្ដើម ដោយឆ្លងកាត់នូវបម្រែបម្រួលរចនាសម្ព័ន្ធ និងការកើនឡើងទំហំវិស័យឧស្សាហកម្មដែលទាក់ទងទៅនឹងវិស័យកសិកម្មដែលមានស្រាប់ ហើយក៏លោកមានការព្រួយបារម្ភអំពីកង្វះពលកម្មនៅខណៈការរីកចម្រើននៃវិស័យឧស្សាហកម្ម។ ហេតុនេះហើយទើបលោកបានបែងចែកប្រទេសជាពីរវិស័យគឺ៖

- **វិស័យកសិកម្ម**

គឺជាវិស័យដែលគ្រាន់តែចិញ្ចឹមជីវភាពនៅជនបទក្នុងវិស័យនេះប្រាក់ឈ្នួលមានកម្រិតទាប ហើយវាពឹងផ្អែកទៅលើដើមទុន កម្លាំងពលកម្មខ្លាំង។

- **វិស័យឧស្សាហកម្ម**

គឺជាវិស័យដែលមានបច្ចេកវិទ្យាទំនើប និងមានអត្រាប្រាក់ចំណូលខ្ពស់ ហើយកំណើនផលិតភាពខ្ពស់ និង មានតម្រូវការពលកម្មកាន់តែច្រើន។

---

[2] (*Rostow's 5 Stages of Economic Growth and Development*): https://www.thoughtco.com/rostows-stages-of-growth-development-model-1434564 បានចូលមើលថ្ងៃទី ១ ឧសភា ២០២៤

### ១.២.៣. ទ្រឹស្តីរបស់លោក Michel.P.Todaro

លោកMichel P.Todaro បានលើកឡើងថា ដើម្បីធ្វើអោយប្រទេសជាតិឈានដល់ការអភិវឌ្ឍយើងត្រូវតែមានកត្តាបីយ៉ាងគឺ៖ ការពន្លឿនoutput តាមរយៈការធ្វើកំណែទម្រង់ផ្នែកស្ថាប័ន និងបច្ចេកវិទ្យា ដែលបានរៀបចំឡើង សម្រាប់បង្កើតផលិតភាពសម្រាប់កសិកម្មនិង អ្នកចិញ្ចឹមសត្វ ដើម្បីបង្កើតតម្រូវការក្នុងស្រុកសម្រាប់ផលិតភាពកសិកម្មដែលមានប្រភពពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារ សកម្មភាពអភិវឌ្ឍន៍ជនបទ ដើម្បីពង្រីកកម្លាំងពលកម្មមិនមែនកសិកម្ម និងវិស័យដទៃទៀតដែលគាំទ្រដោយផ្ទាល់ឬដោយប្រយោលពីសមាគមន៍កសិកម្ម។

## ១.៣. និយមន័យការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វ គឺជាផ្នែកនៃកសិកម្មដែលទាក់ទងនឹងសត្វដែលគេចិញ្ចឹមសម្រាប់យកសាច់ សរសៃ ទឹកដោះគោ ឬផលិតផលផ្សេងទៀតជាដើម។ ការចិញ្ចឹមនេះយើងត្រូវមើលថែទាំប្រចាំថ្ងៃ ការគ្រប់គ្រងរបបអាហារ ការផលិត អាហារូបត្ថម្ភ និងការចិញ្ចឹមជ្រើសរើសពូជ។ ការចិញ្ចឹមសត្វមានប្រវត្តិសាស្ត្រដ៏យូរអង្វែងណាស់មកហើយ ដោយបានចាប់ផ្តើមតាំងពីបដិវត្តន៍យុគថ្មរំលីង នៅពេលដែលសត្វត្រូវបានចិញ្ចឹមជាលើកដំបូង ចាប់តាំងពីឆ្នាំ 13,000 មុនគ.ស។ នៅពេលនៃអរិយធម៌ដំបូងដូចជាអេហ្ស៊ីបបុរាណ គោក្របី ចៀម ពពែ និងជ្រូកត្រូវបានចិញ្ចឹមនៅក្នុងកសិដ្ឋាន។

ការចិញ្ចឹមសត្វគឺជាផ្នែកនៃកសិកម្មដែលទាក់ទងនឹងការបង្កាត់ពូជ ការចិញ្ចឹម និងការថែទាំសត្វក្នុងស្រុក។ វាគឺជាការអនុវត្តដែលប្រើដើម្បីបង្កើនផលិតកម្មបសុសត្វនៃផលិតផលសត្វ។

ការចិញ្ចឹមសត្វ គឺជាការគ្រប់គ្រង និងថែទាំសត្វ ដែលលក្ខណៈហ្សែន និងអាកប្បកិរិយារបស់សត្វត្រូវបានកែលម្អ ដើម្បីរកប្រាក់ចំណេញ។ កសិករមួយចំនួនធំប្រកបរបរចិញ្ចឹមសត្វ។

ក្នុងការចិញ្ចឹមសត្វ ដូចជា មាន់ ទា គោ ពពែ ជ្រូក ជាដើម ត្រូវបានបង្កាត់ជាសាច់។ ក្រៅពីសត្វក្នុងស្រុក សត្វសមុទ្របម្រើជាប្រភពអាហារបំប៉នជំនួស។ អាហារសមុទ្រមានប្រភពនៃសារជាតុចិញ្ចឹមជាច្រើនប្រភេទដូចជាខ្លាញ់ ប្រូតេអ៊ីន វីតាមីន និងសារជាតុរ៉ែ។

## ១.៤. គោលបំណងនៃការអភិវឌ្ឍ

សម្រាប់គោលបំណងនៃការធ្វើការអភិវឌ្ឍគឺមានសមាសធាតុគ្រឹះ ឬតម្លៃស្នូល៣ យ៉ាងដែលជាមូលដ្ឋានគ្រឹះដែលពឹងផ្អែកលើគំនិតនិងគោលការណ៍ប្រតិបិត្តការដើម្បីយល់ដឹងពីអត្ថន័យនេះបាន។ តម្លៃស្នូលទាំងបី គឺចីរភាព ការគោរពខ្លួនឯង និងសេរីភាពដែលបានបង្ហាញនូវគោលបំណងរបស់បុគ្គលនិមួយៗ ណិងសង្គមនានា។ តម្លៃទាំងនោះទាក់ទងនឹងតម្រូវការរបស់មនុស្សជាមូលដ្ឋាន និងវប្បធម៌នានាជារៀងរហូតមក។

ដូច្នេះយើងបានសន្និដ្ឋានបានថា ការអភិឌ្ឍគឺជាសច្ចភាព ជារូបវន្ត និងជាសភាពផ្លូវចិត្តដែរតាមរយៈដូចជា ការរួមផ្សំនៃដំណើរការសង្គមនានាដើម្បីសម្រេចបាននូវជីវិតដែលមានភាពប្រសើរមួយ។ មិនតែប៉ុណ្ណោះទោះបីជាសមត្ថភាពនៃជីវិតល្អបែបណាក៏ដោយយ៉ាងណាក៏ការអភិវឌ្ឍក្នុងសង្គមត្រូវការមានគោលដៅ ៣ ដូចជា៖

១. ដើម្បីបង្កើនលទ្ធភាពដែលអាចរកបាន និងពង្រីកការបែកចែកទំនិញទ្រទ្រង់ជីវិតជាមូលដ្ឋាន ដូចជាមានម្ហូបអាហារ ផ្ទះសម្បែង សុខភាព និងការថែរក្សាសុវត្ថិភាព។

២. ដើម្បីបង្កើនកម្រិតជីវភាពដែលរួមមានការផ្តល់ការងារច្រើនមុខ ការអប់រំប្រសើរជាង មុននឹងយកចិត្តទុកដាក់ខ្លាំងជាងមុនទៅលើតម្លៃវប្បធម៌ និងមនុស្សធម៌ជាបន្ថែមទៅលើចំណូល ខ្ពស់ជាងមុន ហើយដែលធាតុនីមួយៗ ទាំងនេះនឹងជួយលើកកម្ពស់សុខុមាលភាពជាសម្ភារៈថែម ទាំងជួយបង្កើតការគោរពជាតិ និងបុគ្គលមួយរូបៗផងដែរ។

៣. ដើម្បីពង្រីកលំដាប់ផ្នែកសេដ្ឋកិច្ច និងសង្គម ដែលមានបុគ្គលនីមួយៗ និងជាតិនានា គឺត្រូវកាត់បន្ថយការគិតអវជ្ជមាន ដើម្បីកាត់បន្ថយមានទុក្ខសោក និងចាកចេញពីភាពអវិជ្ជា។

## ១.៥. កត្តាដែលជម្រុញអោយមានការអភិវឌ្ឍ

ការអភិវឌ្ឍនៃប្រទេស ឬតំបន់ត្រូវបានជះឥទ្ធិពលដោយកត្តាជាច្រើន ដែលអាចបែងចែកយ៉ាងទូលំទូលាយទៅជាកត្តាសេដ្ឋកិច្ច សង្គម នយោបាយ និងបរិស្ថាន។

នេះជាទិដ្ឋភាពទូទៅនៃកត្តាសំខាន់ៗដែលជំរុញការអភិវឌ្ឍន៍៖

### ១.៥.១. ធនធានមនុស្ស

**ក. កម្លាំងពលកម្ម៖** មានមនុស្សដែលមានចំណេះជំនាញត្រឹមត្រូវដើម្បីធ្វើការមានប្រសិទ្ធភាព។

**ខ. ការអប់រំ វិន័យ៖** ការទទួលបានការអប់រំប្រកបដោយគុណភាព ធ្វើអោយប្រសើរឡើងនូវជំនាញ និងចំណេះដឹង។

**គ. ការលើកទឹកចិត្ត៖** ការលើកទឹកចិត្តដល់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ (R&D) នាំទៅរកផលិតផល និងដំណើរការថ្មីៗ។

### ១.៥.២. ធនធានធម្មជាតិ

**ក. ដី រ៉ែ ប្រេង៖** លទ្ធភាពទទួលបានធនធានធម្មជាតិដូចជា រ៉ែ ទឹក និងដីបង្កបង្កើនផល។

**ខ. គុណភាពនៃបរិស្ថាន៖** ការពារប្រព័ន្ធអេកូឡូស៊ី វិធានការកាត់បន្ថយការរិចរិលបរិស្ថាន និងការបំពុលបរិស្ថាន។

### ១.៥.៣. មូលធន

**ក. ម៉ាស៊ីនរោងចក្រ៖** មានម៉ាស៊ីនទំនើបៗដើម្បីបង្កើនប្រសិទ្ធភាព និងផលិតភាព។

**ខ. ហេដ្ឋារចនាសម្ព័ន្ធ៖** ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ថាមពល និងប្រព័ន្ធទំនាក់ទំនង។

### ១.៥.៤. បច្ចេកវិទ្យា

**ក. វិទ្យាសាស្ត្រ វិស្វកម្ម៖** ការទទួលយកបច្ចេកវិជ្ជាថ្មីជួយបង្កើនផលិតភាព និងប្រសិទ្ធភាព។

**ខ. ការគ្រប់គ្រងដោយនិរន្តរភាព៖** ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

## ១.៦. ឧបសគ្គដែលរារាំងក្នុងការអភិវឌ្ឍ

ប្រទេសជាច្រើន បានឃើញឧបសគ្គជាចម្បងមួយដែលជារនាំងនៃការអភិវឌ្ឍគឺ វដ្តនៃភាពក្រីក្រ។ ទ្រឹស្តីវដ្ត នៃភាពក្រីក្រ អាចពន្យាបានតាមទស្សនៈ២យ៉ាង គឺៈ

- ទស្សនៈផ្គត់ផ្គង់សរុប
- និង ទស្សនៈតម្រូវការសរុប។

### ១.៦.១. ទស្សនៈផ្គត់ផ្គង់សរុប

ដ្យាក្រាមទី ១.១ ទស្សនៈផ្គត់ផ្គង់សរុប[3]




### ១.៦.២. ទស្សនៈតម្រូវការសរុប

ដ្យាក្រាមទី ១.២ ទស្សនៈតម្រូវការសរុប




### ១.៦.៣. សំយោគទស្សនៈទាំងពីរ

ដ្យាក្រាមទី ១.៣ សំយោគទស្សនៈតម្រូវការសរុប និងផ្គត់ផ្គង់សរុប[4]




[3] សារណាបញ្ចប់ការសិក្សាៈ ឡៃ ប៉ូរ៉ាពីន, ការអភិវឌ្ឍន៏វិស័យកសិកម្មនៅប្រទេសកម្ពុជា(២០១៧), ទំព័រ ១០។

[4] សារណាបញ្ចប់ការសិក្សាៈ ឡៃ ប៉ូរ៉ាពីន, ការអភិវឌ្ឍន៏វិស័យកសិកម្មនៅប្រទេសកម្ពុជា(២០១៧), ទំព័រ ១១។

ផលិតភាពទាបជាមូលហេតុរារាំងការអភិវឌ្ឍសេដ្ឋកិច្ចវដ្តនៃភាពក្រីក្រនេះ ឱ្យមនុស្សរស់ នៅក្នុងភាពក្រីក្រដែលជាលទ្ធផល នៃការបណ្តុះបណ្តាលទាប ហើយបណ្តាលឱ្យប្រជាពលរដ្ឋ មានកំណើនយ៉ាងលឿន។ គេមានមធ្យោបាយពីរយ៉ាង ក្នុងការបង្កើនផលិតភាពដើម្បីជំរុញការ អភិវឌ្ឍសេដ្ឋកិច្ចដែលមធ្យោបាយ ២យ៉ាងគឺ៖

**ក. មូលធន និងផលិតភាពកសិកម្ម**

ដើម្បីឱ្យផលិតភាពពលកម្មកើនឡើង ទាមទារឱ្យបង្កើនមូលធនទាំងបរិមាណ និងគុណ ភាពហើយដែលប្រភពធនធានដើម្បីឱ្យសម្រេចគោលដៅនេះបានមកពី ការអនុវត្តនយោបាយ គៀងគរនូវការសន្សំតូចតាច ដែលរាយប៉ាយពាសពេញផ្ទៃប្រទេស ដោយជំរុញឱ្យមហាជនឱ្យ ចូលរួមសន្សំ។ បញ្ចូលខ្លួនទៅនឹងខ្សែសង្វាក់ផលិតកម្ម នៃសមាហរណកម្មសេដ្ឋកិច្ចពិភពលោក (ដើម្បីទទួលបានជំនួយអភិវឌ្ឍន៍ និងឥណទានអភិវឌ្ឍន៍)។

**ខ. ការអភិវឌ្ឍធនធានមនុស្ស**

បង្កើនសមត្ថភាពផលិតកម្មរបស់ពលកម្មតាមរយៈការសិក្សាបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការវិនិយោគធនធានមនុស្សតាមរយៈការថែរក្សាសុខភាព ការបង្កើនសុវត្ថិភាពពលកម្ម ហើយ និងការទប់ស្កាត់កំណើនប្រជាពលរដ្ឋ។[5]

## ១.៧. ប្រវត្តកសិកម្ម

នៅក្នុងប្រវិត្តកសិកម្មយើងបានដឹងថាកសិកម្មគឺជាផ្នែកមួយដ៏សំខាន់នៃអរិយធម៌របស់មនុស្សតាំងពីព្រឹកព្រលឹមដើម្បីធ្វើស្រែចំការ ដាំដំណាំ មើលថែជ្រូកមាន់ទាដែលពួកគាត់ចិញ្ចឹម។ នៅសម័យដើម ប្រជាជនភាគច្រើនជាអ្នកកសិករ ដូច្នេះពួកគាត់ពឹងផ្អែកលើវិស័យកសិកម្មជាអាហារនិងជាចំណូលចិញ្ចឹមគ្រួសារ។ដូច្នេះយើងមកយល់ដំណាក់កាលទាំង៣ ដែលធ្វើអោយមានការធ្វើកសិកម្ម។

**ក. ដំណាក់កាលមិនទាន់មានកសិកម្ម**

តាំងពីសម័យដើមមកមនុស្សយើងមិនទាន់ចេះធ្វើកសិកម្មនៅឡើយ មនុស្សរស់នៅគឺធ្វើការបរបាញ់សត្វ និងការប្រមូលអនុផលព្រៃឈើដើម្បីចិញ្ចឹមជីវិតរបស់ពួកគេ។ ដោយសារតែកំណើនមនុស្សពីមួយថ្ងៃទៅមួយថ្ងៃចេះតែកកើតឡើង និងធ្វើអោយអនុផលព្រៃឈើ និងសត្វព្រៃដែលមានជាច្រើនមានការថយចុះ ដូច្នេះហើយទើបមនុស្សមានការទីតាំងលំនៅពីកន្លែងមួយទៅកន្លែងមួយ ក្នុងគោលបំណងដើម្បីរកចំណីអាហារចិញ្ចឹមជីវិត។

ដោយសារកំណើនមនុស្សចេះតែមានការកើនឡើង បានធ្វើឱ្យអនុផលព្រៃឈើ និងសត្វព្រៃនៅទីតាំងគេរកក្នុងព្រៃមានការថយចុះ ដូច្នេះហើយពួកគេ បានចល័តពីកន្លែងមួយទៅមួយកន្លែងក្នុងគោលបំណងរកទីកន្លែងដែលសម្បូរចំណីអាហារ។ ដោយសារតែមានការផ្លាស់ប្តូរទីលំនៅទើបធ្វើអោយពួកគេបានជួបមនុស្សជា

[5] សារណាបញ្ចប់ការសិក្សា (ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា) និសិត្ស៖ *ឡៃ ប៊ុរ៉ាពីន*, ទំព័រទី ១០&១១។

ច្រើន ដែលមនុស្សមួយចំនួនមានការចេះអាធ្យាស្រ័យគ្នា និងមួយចំនួនទៀតគ្មានការចេះអាធ្យាស្រ័យ ទើបធ្វើអោយមានការកើតជាជម្លោះ និងមានការវាយដណ្តើមទីលំនៅដែលសម្បូរទៅដោយអនុផលព្រៃឈើ។ ពីមួយថ្ងៃទៅមួយថ្ងៃទៅមួយថ្ងៃរស់នៅបានបង្កើតជាគ្រួសារនៅប្រមូលផ្តុំគ្នា។ ចាប់តាំងពីការបង្កើតជាកុលសម្ព័ន្ធពួកគេបានបែងបែកឋានៈ និងតួនាទីបាន ច្បាស់លាស់ក្នុងការគ្រប់គ្រងមានដូចជា មេកន្ទ្រាញជាអ្នកដឹកនាំ ហើយបុរសជាអ្នកបរបាញ់សត្វ ចំណែកឯស្ត្រី និងកុមារជាអ្នកប្រមូលនូវអនុផលព្រៃឈើ។ ទោះបីជាមានការបង្កើតជាកុលសម្ព័ន្ធ ក៏ដោយ ពួកគេទាំងអស់នោះនៅតែបន្តរស់ដោយចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ដោយសារតែសត្វព្រៃ និងអនុផលព្រៃឈើមិនអាចធ្វើការផ្គត់ផ្គង់ដល់ក្រុមកុលសម្ព័ន្ធរបស់ពួកគេបាន ហើយសង្គ្រាមរវាងកុលសម្ព័ន្ធ និងកុលសម្ព័ន្ធបានកើតឡើងជារឿយៗដែលបានបណ្តាលឱ្យ មនុស្សជាច្រើននាក់បានស្លាប់។ ពេលមួយ ពួកគេបានឃើញគ្រាប់រុក្ខជាតិដែលពួកគេបានបោះ ចោលនៅក្បែរទីតាំងពួកគេរស់នៅបានដុះលូតលាស់ល្អ និងផ្តល់ផលមកវិញ។ ម្យ៉ាងវិញទៀត សត្វព្រៃដែលពួកគេបរបាញ់បានអាចរក្សាទុកបានយូរថ្ងៃផងដែរ។ ចាប់តាំងពីពេលនោះមកពួកគេ បានរក្សាទុកនូវគ្រាប់រុក្ខជាតិសម្រាប់ធ្វើការដាំដុះ និងសត្វព្រៃយកមករក្សាទុកផងដែរ។ ពេលនោះ ហើយដែលសញ្ញាណនៃការធ្វើកសិកម្មបានលេចរូបរាងឡើង។

**ខ .ដំណាក់កាលកសិកម្មដោយប្រើកម្លាំងមនុស្ស និងសត្វ**

ដំណាក់កាលកសិកម្មដោយប្រើកម្លាំងមនុស្សនិងសត្វ ឯកសារខ្លះបានលើកឡើងថា មនុស្សបានចេះធ្វើកសិកម្ម និងចិញ្ចឹមសត្វតាំងពីក្នុងកំឡុងពេល១៤,០០ឆ្នាំមុនគ.ស មកម្លេះ។ ឬឯកសារខ្លះបានបង្ហាញថាក្រុមមនុស្សខ្លះចេះដាំដំណាំ និងក្រុមមួយចំនួនទៀតអាចបង្កាត់សត្វដែលបានបរបាញ់មកចញ្ចឹមផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិន មានការបកស្រាយឱ្យបានច្បាស់លាស់នោះទេ ថាការធ្វើកសិកម្មបានកើតឡើងមុនគេនៅទីណា។

តំបន់មួយចំនួនដូចជា តំបន់អេស៊ីប អ៊ីរ៉ាក់ អ៊ីរ៉ង់ បាលេស្ទីន និងអាស៊ីខាងត្បូងគេធ្លាប់ជឿ ថា ជាតំបន់ដែលមានកសិកម្មមុនគេ។ ប្រហែលមុនសតវត្សរ៍ទី៥០មុនគ.ស ប្រទេសចិន ឥណ្ឌា ទើបតែមានការធ្វើកសិកម្មប៉ុណ្ណោះ។ ប្រហែល៦០០០ឆ្នាំមុនគ.ស តំបន់អាស៊ីខាងលិច បានដាំពោត ស្រូវសាលី និងចិញ្ចឹមចៀម ពពែមុនគេ ចំណែកឯតំបន់អាស៊ីអាគ្នេយ៍កំឡុងឆ្នាំ៣០០០ មុនគ.ស បានដាំស្រូវ ចិញ្ចឹមជ្រូក និងមាន់។គួរកត់សម្គាល់ផងដែរ នៅពេលដែលកសិកម្មមានការរីកឡើង មនុស្សបានចាប់ផ្តើមមានលំនៅអចិន្ត្រៃយ៍ ហើយការធ្វើកសិកម្មបានជួយផ្គត់ផ្គង់តម្រូវការរបស់មនុស្សមានគ្រប់គ្រាន់ផងដែរ។

**គ. ដំណាក់កាលទំនើបកម្មកសិកម្ម**

នៅក្នុងឆ្នាំ១៧៦៥ ប្រទេសអង់គ្លេសបានរកឃើញម៉ាស៊ីនដើរដោយចំហាយទឹក ដូច្នេះ ហើយដំណាក់កាលកសិកម្មដោយប្រើកម្លាំង មនុស្ស សត្វ ត្រូវបានបញ្ចប់នៅស.វ.ទី១៨។ វិស័យ កសិកម្មមានការប្រែប្រួលជា

ខ្លាំងគឺ ដោយសាររបកគំហើញនេះបានធ្វើឱ្យការងារក្នុងកសិដ្ឋានជា ច្រើនត្រូវបានគេជំនួសដោយកម្លាំងម៉ាស៊ីន ដែលដើរដោយចំហាយទឹក។ ដោយសារតែប្រជាជន មានកំណើនយ៉ាងខ្លាំង បើទោះបីជាមានការរីកចម្រើនខាងវិស័យកសិកម្មខ្លាំងយ៉ាងណាក៏ដោយក៏ ពិភពលោកយើងនេះនៅតែជួបប្រទះបញ្ហាកង្វះស្បៀងអាហារ។ ហេតុនេះហើយ អ្នកវិទ្យាសាស្ត្រ បានខិតខំស្រាវជ្រាវរកមធ្យោបាយ និងបច្ចេកវិទ្យាថ្មីៗជាច្រើនដើម្បីធ្វើឱ្យវិស័យកសិកម្មកាន់តែ មានភាពជឿនលឿន និងការអភិវឌ្ឍក្នុងគោលបំណងផ្គត់ផ្គង់នូវតម្រូវការស្បៀងអាហារដ៏ច្រើនលើសលប់របស់មនុស្ស។ ការប្រែប្រួលនេះបានឈានដល់បដិវត្តន៍បៃតងដែលជាព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម។ ពេលនោះយើងឃើញថា ទិន្នផលដំណាំស្រូវបាន កើនឡើងចំនួនពីរដង រីឯដំណាំស្រូវសាលីនៅក្នុងប្រទេសអភិវឌ្ឍន៍បានកើនឡើងដល់ទៅបីដង ហើយ ការកើនឡើងនេះដោយសារតែមានពូជទំនើបៗជាច្រើនត្រូវបានគេបង្កើតឡើងដើម្បីបង្កើន ទិន្នផលដំណាំឱ្យទទួលបានជាអតិបរមា។ ការផ្ទុះឡើងនៃបដិវត្តន៍បៃតងត្រូវបានគេកត់សម្គាល់ ឃើញថា គឺបានបែងចែកជាពីរដំណាក់កាលគឺ ក្នុងប្រទេសអភិវឌ្ឍដូចជាប្រទេសកាណាដា អាមេ រិច អឺរ៉ុប និងញ៉ូវសេឡែន បដិវត្តន៍បៃតងនេះបានកើតឡើងនៅកំឡុងឆ្នាំ១៩៥០-១៩៧០ ចំណែកឯបដិវត្តន៍បៃតងដែលបានកើតឡើងនៅអំឡុងទសវត្សរ៍ទី៦០ នៅក្នុងប្រទេសកំពុងអភិវឌ្ឍដូចជាប្រទេសចិន ឥណ្ឌា និងហ្វីលីពីនជាដើម។[6]

## ១.៨. ប្រវត្តិនៃការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វត្រូវបានផ្តួចផ្តើមជាមួយនឹងការចិញ្ចឹមសត្វព្រៃនៅក្នុងសម័យបុរេប្រវត្តិ។ សត្វទាំងនេះរួមមានចៀម និងពពែ ហើយត្រូវបានចិញ្ចឹមជាលើកដំបូងនៅភាគខាងជើងប្រទេសអ៊ីរ៉ាក់។ ការបង្កាត់ពូជការជ្រើសរើសសិប្បនិម្មិតត្រូវបានអនុវត្តនៅក្នុងការចិញ្ចឹមសត្វដើម្បីទទួលបានពូជដែលបង្កើនផលិតកម្មនិងមានតម្លៃខ្ពស់។ ភាពជឿនលឿនក៏ត្រូវបានបង្កើតឡើងក្នុងអាហាររូបត្ថម្ភ និងថ្នាំពេទ្យផងដែរ។ ការអនុវត្តដូចជាការបណ្តុះសិប្បនិម្មិត និងការផ្ទេរអំប្រ៊ីយ៉ុងបានធ្វើឱ្យការចិញ្ចឹមសត្វកាន់តែជឿនលឿនក្នុងលក្ខខណ្ឌនៃបច្ចេកវិទ្យាទំនើប។

ការចិញ្ចឹមសត្វតាមផ្ទះត្រូវបានជំរុញដោយសារតែតម្រូវដ៏ចំបាច់របស់ប្រជាជនដើម្បីយកទៅធ្វើជាអាហារ ហើយវាមានភាពងាយស្រួល ដោយមិនចាំបាច់ធ្វើការបរបាញ់។ លក្ខណៈដែលគួរអោយចង់បានរបស់សត្វក្នុងផ្ទះគឺមានប្រយោជន៍សម្រាប់អ្នកចិញ្ចឹម។

សត្វព្រៃ ចៀម ពពែ ជ្រូក និងគោក្របី ត្រូវបានចិញ្ចឹមជាបណ្តើរៗនៅដើមដំបូងនៃប្រវត្តិសាស្ត្រកសិកម្ម។ ជ្រូកត្រូវបានគេចិញ្ចឹមនៅភាគបូព៌ានៅចន្លោះឆ្នាំ 8,500 និង 8000 មុនគ្រឹស្តសករាជ, និងសត្វគោមកពីតំបន់ព្រៃក្នុងតំបន់នៃប្រទេសទួគី និងប៉ាគីស្ថានសម័យទំនើបប្រហែល 8,500 មុនគស.។ គោជាអត្ថប្រយោជន៍ដ៏អស្ចារ្យ

[6] សារណាបញ្ចប់ការសិក្សាៈ ទ្បែ ប្ញ៉ាពីន ,(២០១៧)ការអភិវឌ្ឍន៏វិស័យកសិកម្មនៅប្រទេសកម្ពុជា ,ទំព័រ ៦-៨។

មួយសម្រាប់អ្នកភូមិ ដោយសារគាត់ផលិតទឹកដោះបានច្រើន ហើយកម្លាំងរបស់គោអាចប្រើជាសត្វធ្វើការ ទាញនង្គ័លដើម្បីបង្កើនទិន្នផលដំណាំ និងអូសរទេះ ហើយក្រោយមកក៏មានរទេះ ដើម្បីនាំយកផលពីស្រែមកផ្ទះ។ សត្វពាហនៈត្រូវបានប្រើប្រាស់ជាលើកដំបូងប្រហែល 4,000 មុនគស នៅមជ្ឈិមបូព៌ា ដោយបង្កើនផលិតកម្មកសិកម្មយ៉ាងច្រើន។

ការចិញ្ចឹមសត្វមានបួនប្រភេទ ដោយផ្អែកលើប្រភេទសត្វមានដូចជា៖

**ក .ការចិញ្ចឹមគោ**

គោ ក្របី ពពែ និងចៀម គឺជាប្រភេទបសុសត្វមួយចំនួនដែលអាចប្រើសម្រាប់ផលិតទឹកដោះ ឬការងារកសិកម្ម ដូចជាការភ្ជួររាស់ និងស្រោចស្រពជាដើម។ កសិករភាគច្រើនចិញ្ចឹម និងថែទាំសត្វទាំងនេះ ដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគេ។ សត្វ Milch គឺជាប្រភេទសត្វដែលផ្តល់ទឹកដោះគោសម្រាប់មនុស្ស។ ទឹកដោះគោ ឈីស ក្រែម និងប៊ឺ គឺជាឧទាហរណ៍នៃផលិតផលទឹកដោះគោដែលផលិតពីទឹកដោះគោ។ ផលិតផលប្រភេទនេះត្រូវបានផលិតយ៉ាងច្រើននៅតាមរោងចក្រ ហើយលក់យកចំណេញ។ គោក៏ជាសត្វដែលគេចិញ្ចឹមសម្រាប់យកជាសាច់ដែរ។

**ខ.ការចិញ្ចឹមបុសបក្សី**

បសុបក្សីសំដៅលើការចិញ្ចឹមបក្សីក្នុងស្រុកសម្រាប់ជាអាហារ ។ ទាំងនេះរួម(សាច់ ឬ ស៊ុត) បញ្ចូលសត្វស្លាបដូចជាមាន់និងបុសបក្សីដទៃទៀត។ វាមានសារៈសំខាន់ណាស់ក្នុងការបែងចែករវាងbroilers និងស្រទាប់នៅក្នុងឧស្សាហកម្មបសុបក្សី។

**គ.ការចិញ្ចឹមត្រី**

ប្រភេទសត្វក្នុងទឹកជាច្រើន ដូចជាត្រី គឺជាអ្នកផ្គត់ផ្គង់ប្រូតេអ៊ីនដ៏ល្អ។ មានវិធីពីរយ៉ាងក្នុងការចិញ្ចឹមត្រី៖ ប្រើប្រាស់ធនធានធម្មជាតិ ឬសិប្បនិម្មិត។ ត្រីច្រើនប្រភេទអាចរកបាននៅក្នុងធនធានធម្មជាតិដូចជាសមុទ្រ បឹង ទន្លេ ។ល។ ជាការចិញ្ចឹមត្រីត្រូវបានអនុវត្តនៅទូទាំងពិភពលោកតែ 62% នៃការផ្គត់ផ្គង់សរុបរបស់ពិភពលោកគឺមកពីប្រទេសចិន។

**ឃ. ការចិញ្ចឹមឃ្មុំ**

ឃ្មុំត្រូវបានគេចិញ្ចឹមក្នុងសិតសក់សិប្បនិម្មិតទ្រង់ទ្រាយធំដើម្បីទាញយកទឹកឃ្មុំក្នុងឧស្សាហកម្មចិញ្ចឹមឃ្មុំ។ ពាក្យជំនួសសម្រាប់ការចិញ្ចឹមឃ្មុំគឺ apiculture ។ ការរក្សាឃ្មុំនៅក្នុង apiary ឬ bee yard ត្រូវបានគេស្គាល់ថាជា apiary ។ ឃ្មុំត្រូវបានបង្កាត់ពូជសម្រាប់ទឹកឃ្មុំ និងក្រមួនឃ្មុំ ដែលត្រូវបានគេប្រើក្នុងឧស្សាហកម្មអាហារ។

មានវិធីជាច្រើនក្នុងការប្រើប្រាស់ទឹកឃ្មុំ ដូចជាក្នុងម្ហូបអាហារ ថ្នាំពេទ្យ គ្រឿងសំអាងជាដើម ជាលទ្ធផល ការចិញ្ចឹមសត្វក៏ជាផ្នែកសំខាន់មួយនៃឧស្សាហកម្មផងដែរ។[7]

## ១.៩. សារៈសំខាន់ក្នុងវិស័យកសិកម្មតាមរយៈការចិញ្ចឹមសត្វ

### ១.៩.១. តួនាទីរបស់បសុសត្វ

តួនាទីយ៉ាងសំខាន់ៗរបស់បសុសត្វក្នុងកសិកម្មប្រពៃណី ភាគច្រើននៃអ្នកមានបំណង បង្កើនផលិតភាពបសុសត្វ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពេលខ្លះមានការយល់ច្រឡំអំពីតួនាទីរបស់វា។

បសុសត្វជាបញ្ហាមួយដែលលើកយកមកពិចារណាដែរ ព្រោះថាដំណាំ និងសត្វប្រកួត ប្រណាំងគ្នាចំពោះធនធាន តែមួយតាមធម្មជាតិ មនុស្សត្រូវការគ្រាប់ធុញ្ញជាតិ ជាងការផ្តល់ ធញ្ញជាតិនោះឱ្យសត្វ ដើម្បីយកសាច់សត្វបរិភោគ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងកសិកម្ម ប្រពៃណីបសុសត្វមានតួនាទីយ៉ាងសំខាន់ជាច្រើនដូចជា៖

**ទ្រនាប់ និងអ្នកពង្រីកនៃការផ្គត់ផ្គង់ចំណីអាហារ៖** សត្វពាហនៈនៃគ្រួសារកសិករ ផ្តល់នូវ ការការពារយ៉ាងពិសេសដល់អ្នកទាំងនោះ គឺមានតួនាទីជា ទ្រនាប់ រវាង គ្រួសារ និង ភាពមិន ទៀងទាត់នៃការផ្គត់ផ្គង់ចំណីអាហារ។ សត្វពាហនៈគឺជា ធនាគារសន្សំ ។ កសិករអាចវិនិយោគ ទៅសត្វពាហនៈ នៅពេលដែលសត្វទាំងនោះធំធាត់កសិករអាចសម្លាប់ធ្វើជាចំណីអាហារ ឬលក់ នៅពេលមានការរអាក់រអួលក្នុងការដាំដុះ។ នៅក្នុងកសិកម្មប្រពៃណីបសុសត្វមិនប្រកួតប្រណាំង ដោយផ្ទាល់ជាមួយដំណាំទេ ព្រោះវាស៊ីតែកាកសំណល់របស់ដំណាំ ស៊ីអ្វីដែលកំពប់ប្រឡាក់ និង ខូច និងជាទូទៅអ្វីដែល ពង្រីក ការផ្គត់ផ្គង់ចំណីអាហារតែប៉ុណ្ណោះ។ សត្វពាហនៈភាគច្រើនជា សត្វទំពារអៀង (គោ ក្របី សេះ ចៀម ពពែ) ស៊ីស្មៅជាអាហារ និងចំណីសត្វផ្សេងៗដែលមនុស្ស មិនអាចនឹងកែច្នៃទៅជាផលិតផលសម្រាប់ការប្រើប្រាស់របស់គេ។ ជាការពិតណាស់ បសុសត្វ ផ្តល់នូវការរួមចំណែកយ៉ាងសំខាន់ សម្រាប់ពង្រីកគុណភាពនៃអាហាររូបត្ថម្ភតាមរយៈការផ្តល់ សាច់ ទឹកដោះគោ និងស៊ុត។ ចំនួនដ៏តូចនៃអាហារប្រកបដោយប្រូតេអ៊ីនកម្រិតខ្ពស់ អាចមាន ឥទ្ធិពលយ៉ាងសំខាន់ដល់សុខភាពរបស់មនុស្ស។

**ជាប្រភពកម្តៅ ស្បែក និងរោម៖** លាមកសត្វពាហនៈគឺជាប្រភពយ៉ាងសំខាន់សម្រាប់ធ្វើជី និងជាប្រភពសម្រាប់កម្តៅក្នុងប្រទេសជាច្រើន។ លាមកសត្វបន្ថែមនូវជី និងរូបធាតុដល់ដី។ នៅ ក្នុងប្រទេស ឬតំបន់ខ្លះដែលពុំសូវសម្បូរឈើនោះ លាមកសត្វ ត្រូវបានគេយកទៅហាលហើយ ប្រើប្រាស់ជាប្រភពកម្តៅ។ នៅក្នុងប្រទេសជាច្រើន ប្រភេទនៃការប្រើប្រាស់លាមកសត្វទាំងពីរ ខាងលើមានការប្រកួតប្រជែងគ្នា។ លាមកសត្វដែលដុតហើយមិនអាចប្រើជាជីបានទេ។ បើយក ធ្វើជីត្រូវខ្វះប្រភពកម្តៅ និងបញ្ច្រាសមកវិញ។ ផលិតផលសត្វ

[7] Types of Animal Husbandry បានចូលមើលថ្ងៃទី ៧ខែមិថុនា ២០២៤

មួយចំនួន ត្រូវបានគេយកមកប្រើ យ៉ាងខ្ជះខ្ជាយនៅក្នុងសង្គមប្រពៃណី។ សម្លៀកបំពាក់ និងភួយអាចធ្វើពីស្បែកសត្វ និងរោមសត្វ ផ្សេងៗដូចជា គោ ក្របី ចៀម ពពែ និង បសុសត្វផ្សេងទៀត។

**កម្លាំង និងការដឹកជញ្ជូន៖** នៅក្នុងប្រទេសជាច្រើន បសុសត្វជាប្រភពចម្បងនៃកម្លាំង។ សត្វទាំងនោះជួយក្នុងការភ្ជួររាស់ស្រែ ដឹកជញ្ជូនផលិតផលទៅកាន់ទីផ្សារ និងបំពេញការងារ ផ្សេងៗ ដូចជា កិនអំពៅ ជាន់កណ្តាប់ស្រូវជាដើម។ ត្រាក់ទ័រគឺជាការរកឃើញថ្មីនៅក្នុងពិភព លោក។ ការវិនិយោគយ៉ាងធំធេង ដើម្បីទិញត្រាក់ទ័របានធ្វើឱ្យ កសិករប្រពៃណីមានការលំបាក យ៉ាងខ្លាំង។ ដូចនេះការជំនួសកម្លាំងសត្វពាហនៈ ដោយគ្រឿងយន្ត នៅក្នុងតំបន់ជាច្រើននៃ ប្រទេសកំពុងអភិវឌ្ឍន៍អាចទាមទាររយៈពេលច្រើនឆ្នាំ។

**សង្គម និងវប្បធម៌៖** បសុសត្វ ដោយឡែក គោ ក្របី និងពពែ មានតម្លៃយ៉ាងខ្ពស់ នៅក្នុង ប្រទេសខ្លះសម្រាប់មូលហេតុសង្គម និងវប្បធម៌។ ឋានៈក្នុងសង្គមរបស់គ្រួសារមួយ គេអាច កំណត់តាមចំនួនសត្វពាហនៈរបស់គ្រួសារនោះ។ គោ ក្របី គឺជាវត្ថុអនុស្សាវរីយ៍ ឬរង្វាន់នៅក្នុង ពិធីបុណ្យខ្លះៗ។ ដោយសារបសុសត្វមានតួនាទីសេដ្ឋកិច្ចយ៉ាងចម្បង។ សត្វទាំងនោះក៏មានតួ នាទីផ្នែកសង្គម និងវប្បធម៌ដែរ។ ជាការពិតណាស់ តួនាទីនេះមានការវិវត្តន៍ដោយសារភាព សំខាន់របស់វាជាមូលធន និងទ្រព្យសម្បត្តិសម្រាប់រកប្រាក់ចំណូល។[8]

### ១.៩.២. សារៈសំខាន់នៃវិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ

វិស័យកសិកម្មមិនត្រឹមតែបានចូលរួមចំណែក ឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺថែម ទាំងបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការសង្គម ក៏ដូចជាការចូលរួមចំណែក កាត់បន្ថយភាព ក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ។ ពោលគឺវិស័យកសិកម្ម អាចដោះស្រាយបាននូវការងារធ្វើ របស់ប្រជាជនរហូតដល់ប្រមាណជិត ៧០% និងអាចចូលរួមមួយចំណែកធំដល់ការកាត់បន្ថយ ភាពក្រីក្រ តាមរយៈការធ្វើផលិតកម្មកសិកម្មនេះ។ កន្លងមកនេះ ដោយសារតែការវិវត្តន៍ជឿន លឿននៃវិស័យ កសិកម្ម អត្រាភាពក្រីក្ររបស់ប្រជាជនកម្ពុជា បានធ្លាក់ចុះពី ២៩.៩% ក្នុងឆ្នាំ ២០០៨ មកត្រឹម ២២.៩% ក្នុងឆ្នាំ២០០៩ ហើយអត្រានេះបានបន្តធ្លាក់ចុះដល់ ២១.១% ក្នុងឆ្នាំ ២០១០ និង ១៩.៨% ក្នុងឆ្នាំ២០១១។ ដូចនេះ គេអាចវាយតម្លៃបានថា កម្ពុជាអាចកាត់បន្ថយភាព ក្រីក្របានប្រមាណជាង ១% ក្នុងមួយឆ្នាំ។ សក្តានុពលភាព សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ដូចជាកត្តាដីកសិកម្មដែលអាចពង្រីកផលិតកម្មកសិកម្ម លទ្ធភាពបង្កើនទិន្នផលដំណាំ ប្រភព ធនធាន ទឹកនិងការស្រោចស្រព កម្លាំងពលកម្មកសិកម្ម។ល។ នឹងអាចជំរុញការរីកលូតលាស់ សេដ្ឋកិច្ចជនបទ និងអាចធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនថែមទៀត។[9]

---

[8] សារណាបញ្ចប់ការសិក្សា (ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា) និសិត្ស៖ *ឡៃ ប៉ូរ៉ាពីន*, ទំព័រទី ១៨&១៩។

[9] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៣-២០១៤ (ភ្នំពេញ៖ *ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៨)*, ១៤។

### ១.៩.៣. ការបរិភោគបសុត្វ និងប្រាក់ចំណូល

ដោយសារវាជាប្រភពផ្តល់ប្រូតេអ៊ីន ផលិតផលបសុសត្វ បន្តដើរតួនាទីបន្តិចបន្តួចនៅក្នុង ការផ្តល់នូវជីវជាតិជាមធ្យម ដល់ប្រជាជនកម្ពុជានៅតាមជនបទ បើគេធៀបនឹងការបរិភោគត្រី។ លោក Maclean បាន ប៉ាន់ស្មានថា ការបរិភោគសាច់បសុសត្វប្រចាំឆ្នាំក្នុងមនុស្សម្នាក់ គឺប្រហែល ១៧.៥គីឡូក្រាម ដែលក្នុងនោះការបរិភោគសាច់ជ្រូកមាន ៨គីឡូក្រាម ការបរិភោគសាច់បសុ បក្សីមាន ៦.៥គីឡូក្រាម ការបរិភោគសាច់គោក្របីមាន ៣គីឡូក្រាម។ បើធៀបជាមួយនឹងការ សិក្សាស្ដីពីការបរិភោគត្រី បានបញ្ជាក់ថា ការបរិភោគត្រីជាមធ្យមក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ មាន ប្រមាណ ២៧-៣៨គីឡូក្រាម។ ការប៉ាន់ស្មានថ្នាក់ជាតិបានបញ្ជាក់ថា ផលិតផលបសុសត្វមាន ប្រមាណ ១/៣នៃសាច់ដែលបានបរិភោគ ដែលអត្រានេះ ហាក់ដូចជាមានកម្រិតទាបយ៉ាងខ្លាំង នៅតាមតំបន់ជនបទ។ នេះក៏ព្រោះ គោ ក្របី និងជ្រូក គឺជាប្រភពចំណូលយ៉ាងសំខាន់សម្រាប់គ្រួសារកសិករ។ ជ្រូកត្រូវគេចិញ្ចឹមដោយផ្ទាល់សម្រាប់លក់យកប្រាក់ ចំណែកឯ គោ ក្របី ត្រូវ បានគេចិញ្ចឹមសម្រាប់ធ្វើជាកម្លាំងអូសទាញយ៉ាងសំខាន់ និងលក់ទៅឱ្យឈ្មួញសត្តឃាត។[10]

### ១.១០. និរន្តរ៍ភាពតាមរយៈការចិញ្ចឹមសត្វ

ដើម្បីអនុវត្តប្រកបដោយនិរន្តរ៍ភាពតាមរយៈការចិញ្ចឹមសត្វគឺត្រូវ៖

- **ការចិញ្ចឹមសត្វតាមបែបអេកូឡូស៊ី៖** ការលើកទឹកចិត្ត និងគាំទ្រការអនុវត្តន៍កសិកម្មបែបអេកូឡូស៊ីអាចរួមចំណែកដល់ការចិញ្ចឹមសត្វប្រកបដោយនិរន្តរភាព។ នេះពាក់ព័ន្ធនឹងការរួមបញ្ចូលបសុសត្វជាមួយនឹងផលិតកម្មដំណាំ ការលើកកម្ពស់ជីវចម្រុះ និងកាត់បន្ថយការពឹងផ្អែកលើធាតុចូលពីខាងក្រៅ។
- **ការគ្រប់គ្រងទឹក៖** ការអនុវត្តការអភិរក្សទឹក និងការគ្រប់គ្រងក្នុងការចិញ្ចឹមសត្វ ដូចជាការប្រមូលផលទឹកភ្លៀង វិធីសាស្រ្តស្រោចស្រពប្រកបដោយប្រសិទ្ធភាព និងការកែច្នៃទឹកអាចកាត់បន្ថយការប្រើប្រាស់ទឹក និងកាត់បន្ថយផលប៉ះពាល់បរិស្ថាននៃការធ្វើកសិកម្ម។
- **ការគ្រប់គ្រងសារធាតុចិញ្ចឹម៖** ការអនុវត្តយុទ្ធសាស្រ្តគ្រប់គ្រងសារធាតុចិញ្ចឹមប្រកបដោយប្រសិទ្ធភាព ដូចជាការជីកំប៉ុសលាមកសត្វ ការប្រើប្រាស់ជីសរីរាង្គ និងការលើកកម្ពស់ឡជីវឧស្ម័នសម្រាប់ការគ្រប់គ្រងកាកសំណល់ អាចជួយក្នុងការកែលម្អជីជាតិដី និងកាត់បន្ថយការពឹងផ្អែកលើធាតុសំយោគ។
- **សមាហរណកម្មកសិកម្មរុក្ខាប្រមាញ់៖** ការរួមបញ្ចូលដើមឈើ និងគុម្ពឈើនៅក្នុងប្រព័ន្ធចិញ្ចឹមសត្វអាចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា ការប្រមូលកាបូន ការកែលម្អ microclimate ផលិតកម្មចំណី និងប្រភពចំណូលចម្រុះ។

---

[10] ព្រំ តុលា, និង Brue Mckenney, ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទប្រទេសកម្ពុជា (ភ្នំពេញ៖ វិទ្យាស្ថាន បណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ២០០២), ៤១។

- **ការគ្រប់គ្រងសុខភាពបសុសត្វ៖** ការសង្កត់ធ្ងន់លើវិធានការថែទាំសុខភាពបង្ការ កម្មវិធីចាក់វ៉ាក់សាំងត្រឹមត្រូវ និងការថែទាំសត្វទាំងមូលអាចកាត់បន្ថយតម្រូវការថ្នាំអង់ទីប៊ីយោទិច និងអន្តរាគមន៍គីមី លើកកម្ពស់សុខុមាលភាពសត្វ និងកាត់បន្ថយការបំពុលបរិស្ថាន។
- **ការចូលរួមសហគមន៍៖** ការចូលរួមសហគមន៍មូលដ្ឋានក្នុងការអនុវត្តការចិញ្ចឹមសត្វប្រកបដោយនិរន្តរភាព តាមរយៈការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពអាចជំរុញអារម្មណ៍នៃភាពជាម្ចាស់ និងលើកកម្ពស់ការទទួលយកវិធីសាស្ត្រកសិកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន។

ដូចនេះ តាមរយៈការលើកកម្ពស់ការអនុវត្តប្រកបដោយនិរន្តរភាពទាំងនេះក្នុងការចិញ្ចឹមសត្វ ប្រទេសកម្ពុជាអាចកាត់បន្ថយការបោះជំហានអេកូឡូស៊ីនៃការចិញ្ចឹមសត្វ ធ្វើអោយប្រសើរឡើងនូវភាពធន់នឹងបញ្ហាប្រឈមបរិស្ថាន និងលើកកម្ពស់និរន្តរភាពយូរអង្វែងនៃវិស័យកសិកម្ម។

# ជំពូកទី ២

# ស្ថានភាពវិស័យកសិកម្មនៅ
# ប្រទេសកម្ពុជា

# ជំពូកទី ២
# ស្ថានភាពវិស័យកសិកម្មនៅប្រទេសកម្ពុជា

## ២.១. ស្ថានភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជា

ក្នុងលក្ខណៈជាសេដ្ឋកិច្ចបើកចំហតូចមួយ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ក្នុងពេលចំពោះមុខ វាអាស្រ័យលើបរិយាកាសខាងក្រៅ។ ពិតហើយ សេដ្ឋកិច្ចកម្ពុជាហាក់ចាប់ផ្តើមមានកំណើនយឺត ចាប់តាំងពីពេលមានវិបត្តិហិរញ្ញវត្ថុ សាកលឆ្នាំ២០០៨-០៩ មក ទោះជាមិនគិតបញ្ចូលនូវការធ្លាក់ ចុះសេដ្ឋកិច្ចយ៉ាងគំហុកនៅឆ្នាំ២០០៩ ក្តី។ កំណើនសេដ្ឋកិច្ចចំនួនបួនឆ្នាំ ពីឆ្នាំ២០០៨-១២ (មិនគិត ឆ្នាំ២០០៩) មានជាមធ្យមប្រហែល ៦.៦% ដែលទាបជាងអត្រាប្រចាំឆ្នាំជាមធ្យម ១១% ពីឆ្នាំ ២០០៤-២០០៧ គឺនៅមុនពេលមានវិបត្តិសកល។ ការថយចុះកំណើនមាន លក្ខណៈកាន់តែ ធ្ងន់ធ្ងរថែមទៀត ក្នុងវិស័យមិនមែនកសិកម្ម ជាពិសេសវិស័យឧស្សាហកម្ម។ កំណើនប្រចាំឆ្នាំក្នុង វិស័យឧស្សាហកម្ម ដែលមានអត្រាជាមធ្យម ១៤% ពីឆ្នាំ២០០៤-០៧ បានធ្លាក់មកត្រឹម ៨៥% ពី ឆ្នាំ២០០៨-១២ (មិនគិតឆ្នាំ២០០៩)។ ដូច្នេះស្ថានភាពសេដ្ឋកិច្ចក្នុងពេលចំពោះមុខ វាផ្សារភ្ជាប់ជាខ្លាំងទៅនឹងកម្លាំងទើបឡើងវិញនៃសេដ្ឋកិច្ចសាកល។

នៅក្នុងឯកសារចេញផ្សាយនៅខែតុលា ២០១២ ស្តីពី អនាគតសេដ្ឋកិច្ចពិភពលោក IMF (International Monetary Fund: មូលនិធិរូបិយវត្ថុអន្តរជាតិ) បានប៉ាន់ស្មានថា ផសស ពិភពលោក មានកំណើនប្រហែល ៣.៦% នៅឆ្នាំ២០១៣ ឬកើនឡើងបន្តិច បើធៀបនឹងកំណើន ៣៣% នៅ ឆ្នាំ២០១២។ ជារួម តួលេខនេះបង្ហាញពីការកែតម្រូវ បញ្ចុះយ៉ាងខ្លាំងនូវអត្រាកំណើន ផសស សាកល សម្រាប់ឆ្នាំ ២០១៣ ដែល IMF បានបញ្ជាក់ថាមានកម្រិត ៣.៩% និង ៤.១% តាមការ ព្យាករណ៍កាលពីខែកក្កដា ២០១២ និងមេសា ២០១២។ កំណើន ផសស នៅសហរដ្ឋអាមេរិករំពឹង ថា កើនលើស ២% បន្តិច នៅឆ្នាំ២០១៣ រីឯកំណើន នៅតំបន់អឺរ៉ុបគេព្យាករណ៍ថាមានកម្រិត ខ្សោយ ហើយ ផសស នៅប្រទេសជប៉ុន រំពឹងថា នឹងធ្លាក់ចុះពី ២២% នៅឆ្នាំ២០១២ មកត្រឹម ១.១% នៅឆ្នាំនេះ។ ការព្យាករណ៍សម្រាប់ប្រទេស មានសេដ្ឋកិច្ចកំពុងលេចធ្លោឡើង នៅអាស៊ី មានតួលេខល្អ ប៉ុន្តែចំណងទាក់ទងច្រើនជាមួយ សហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ ប្រហែលធ្វើឱ្យ ប្រទេសទាំងនោះ មិនមានកំណើនខ្លាំងក្លាប៉ុន្មានទេក្នុងឆ្នាំនេះ។[11]

ដោយសារការព្យាករណ៍ ពីសេដ្ឋកិច្ចសាកលវាមិនសូវល្អនោះ ការនាំចេញរបស់កម្ពុជា ទំនងមិនអាចស្ទុះឡើង បានច្រើនទេនៅឆ្នាំ២០១៣។ នាបច្ចុប្បន្ន ការនាំចេញរបស់កម្ពុជាទៅ សហរដ្ឋអាមេរិក មានប្រហែល ៣៨% (ធៀបនឹង ៧០% ក្នុងឆ្នាំ២០០០) ទៅសហភាពអឺរ៉ុប ៣៥% (២០% ក្នុងឆ្នាំ២០០០) និងទៅប្រទេសផ្សេងទៀត ២៧% (១០% ក្នុងឆ្នាំ ២០០០)។ ការបន្តរើប សេដ្ឋកិច្ចយឺតៗនៅសហរដ្ឋអាមេរិក និងអឺរ៉ុប មិនផ្តល់ប្រផ្នូលល្អ សម្រាប់ការនាំចេញរបស់កម្ពុជា នោះទេ។ យោងតាមនិន្នាការបច្ចុប្បន្ន ការនាំចេញទំនងកើនឡើងប្រហែល ២៦% ដែលស្រដៀង គ្នានឹងតួលេខ ឆ្នាំ ២០១២។ ចំណូលពីវិស័យទេសចរណ៍ ប្រហែលអាចរក្សាលំនឹងបានមួយរយៈដោយសារមួយចំណែក មានភ្ញៀវទេសចរមកពីកាន់តែច្រើន ប្រទេសឡើងចូលមកកម្ពុជា

[11] CDRI, *សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១២-២០២៣* (២០១៣, ក.ស.ប. ៖ ភ្នំពេញ៖ រ)

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ការអនុវត្តកម្មវិធី ទិដ្ឋការរួម រវាងថៃ និងកម្ពុជា (ទម្រង់អនុវត្តនៅអាស៊ាននៃ គម្រូប្រព័ន្ធទិដ្ឋាការ Schengen របស់សហភាពអឺរ៉ុប) ដែលបានដាក់អនុវត្តនៅខែធ្នូ ២០១២ និងផ្លូវ ហោះហើរថ្មីរបស់ ក្រុមហ៊ុនអាកាសចរណ៍ Tiger Airline ពីភ្នំពេញ ទៅសិង្ហបុរី ដែលបានចាប់ ដំណើរការក្នុងខែតុលា ២០១២ ទំនងអាចជួយដល់វិស័យទេសចរណ៍។

ដោយបន្តមានលទ្ធផលរឹងមាំក្នុងវិស័យអចលនទ្រព្យ និងសំណង់កម្ពុជាអាចរក្សាកំណើន ផសស សម្រាប់វិស័យកសិកម្មក្នុងអត្រាប្រហែល ៧៥%។ ប្រសិនបើមិនមានគ្រោះធម្មជាតិអ្វី ធ្ងន់ធ្ងរទេនោះ កំណើន ផសស ៤៥%ក្នុងវិស័យកសិកម្ម ប្រហែលជាអាចរក្សាបាន។ តាមនេះ កំណើន ផសស សរុប សម្រាប់ឆ្នាំ ២០១៣ អាចមានប្រហែល ៧%។ អត្រាកំណើនទំហំប៉ុណ្ណោះ មិនគួរដាក់សម្ពាធអ្វីជ្រុលទៅលើអតិផរណា ឬឱនភាពគណនីចរន្តនោះទេ ហើយគួរតែអាចជួយ រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបាន។

ទោះជាយ៉ាងណាក្តី ដូច IMF បានដាស់តឿនដែរ និន្នាការផុសឡើងមួយចំនួន ដូចជា ការ រីកធំយ៉ាងឆាប់រហ័សនៃឥណទានធនាគារ ការថយចុះកម្លាំងខាងហិរញ្ញវត្ថុជាលទ្ធផលនៃចំណូល ពន្ធធ្លាក់កំណើន និងបំណុលធំៗដែលអាចកើតមាន (ដោយសាររដ្ឋាភិបាលអនុវត្តគម្រោងជាដៃ គូរវាងរដ្ឋ-ឯកជន ក្នុងវិស័យថាមពល) អាចបង្កជាហានិភ័យដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ ក្នុង ប៉ុន្មានឆ្នាំខាងមុខនេះ។ ពិតហើយអ្នកគ្រប់គ្រងហិរញ្ញវត្ថុត្រូវតែប្រុងប្រយ័ត្ន និងពិនិត្យតាមដាន ការវិវត្តផ្នែកឥណទានឱ្យបានដិតដល់។ ប៉ុន្តែអត្រាខ្ពស់នៃកំណើនឥណទាន ក្នុងប៉ុន្មានឆ្នាំថ្មីៗ អាចបណ្តាលជាចម្បងមកពីកំណែទម្រង់រចនាសម្ព័ន្ធ ដូចជា ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចនានា ឆ្នាំ២០០៩ (លុបបំបាត់របាំងចំពោះការប្រើប្រាស់ចលនទ្រព្យធ្វើជាវត្ថុនានា) បទបញ្ញត្តិថ្មីដែលអនុញ្ញាតឱ្យ ការិយាល័យឥណទាន ប្រមូល និងចែកចាយពត៌មានឥណទានវិជ្ជមាន និងអវិជ្ជមាន និងការបង្កើតការិយាល័យឥណទានដំបូងនៅកម្ពុជាក្នុងឆ្នាំ២០១២។

ក្រោយពីធ្លាក់ចុះកំណើនដោយសារជំងឺកូវីដ-១៩ សេដ្ឋកិច្ចរបស់កម្ពុជាកំពុងងើបឡើងវិញ ដោយមានការទ្រទ្រង់ពីវិស័យនាំចេញដែលនៅមានភាពរឹងមាំ។ ប៉ុន្តែ កម្ពុជានៅតែប្រឈមមុខនឹងឧបសគ្គច្រើនទៀតនៅក្នុងសេដ្ឋកិច្ចសកលលោក ខណៈដែលសកម្មភាពពាណិជ្ជកម្មពិភពលោកមានកំណើនយឺត។ ធនាគារពិភពលោកបានកែសម្រួលឡើងវិញនូវការព្យាករអំពីកំណើនផ.ស.សពិតរបស់កម្ពុជា នឹងមាន ៤,៨ភាគរយ ក្នុងឆ្នាំ២០២២ ដោយឃើញថា សេដ្ឋកិច្ចកំពុងមានសកម្មភាពរើបឡើងវិញជាទូទៅ។ ការនាំចេញទំនិញសម្លៀកបំពាក់, ទំនិញធ្វើដំណើរ និងទំនិញស្បែកជើង នៅមានសកម្មភាពរស់រវើកគួរឱ្យកត់សម្គាល់ដដែល។ ការរកចំណូលពីវិស័យសេវាកម្ម ពិសេសពីផ្នែកធ្វើដំណើរនិងទេសចរណ៍ ក៏មានភាពប្រសើរឡើងដែរ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រ "រស់នៅជាមួយកូវីដ-១៩" នាចុងឆ្នាំកន្លងទៅ។ អតិផរណានៅកម្ពុជាកំពុងកើនខ្ពស់ជាងមុន និងបង្កផលប៉ះទង្គិចខ្លាំងទៅលើជីវភាពរបស់គ្រួសារក្រីក្រ ដែលក្នុងនោះមានគ្រួសារខ្លះត្រូវបានបង្ខំចិត្តកាត់បន្ថយបរិមាណអាហារហូបចុករបស់ខ្លួន និងឈប់ឱ្យកូនទៅរៀនទៀតផង។ បញ្ហានេះអាចជះឥទ្ធិពលអាក្រក់

យូរអង្វែងទៅលើមូលធនមនុស្ស ដោយវានឹងបណ្តាលឱ្យបាត់បង់នូវផលិតភាពរបស់ពលករ និងសុខុមាលភាព និងបង្កវិសមភាពនៃការទទួលបានចំណូល។ គោលនយោបាយរូបិយវត្ថុបន្តដើរតួសំខាន់ក្នុងការងើបឡើងវិញរបស់សេដ្ឋកិច្ច ក្នុងនោះ ជំនឿទុកចិត្តលើប្រព័ន្ធធនាគារនៅមានកម្រិតខ្ពស់។ កំណើនឥណទានក្នុងស្រុករក្សាបានភាពរឹងមាំ ហើយអត្រាប្តូរប្រាក់ក៏មានស្ថិរភាពដែរ។ ប្រាក់ចំណូលក្នុងស្រុកឥឡូវនេះមានកំណើនស្ទុះងើបពេញលេញវិញហើយ រីឯការចំណាយត្រូវបានរំពឹងទុកថានឹងថមថយល្បឿនបន្តិចវិញ បន្ទាប់ពីមានការចំណាយច្រើនទៅលើវិធានការសង្គ្រោះពាក់ព័ន្ធនឹងជំងឺរាតត្បាត នៅក្នុងឆ្នាំកន្លងទៅ។ តាមរយៈនេះ ឱនភាពសារពើពន្ធត្រូវបានព្យាករថានឹងរួមតូចបន្តិចមកវិញ បើទោះបីជាវានៅតែមានទំហំធំគឺ ៤,៦ភាគរយនៃផ.ស.សក៏ដោយ ហើយឱនភាពនេះនឹងត្រូវបានបំពេញមួយផ្នែកធំតាមរយៈការខ្ចីបុលពីខាងក្រៅប្រទេស។[12]

ទន្ទឹមនឹងការងើបឡើងវិញនៃសេដ្ឋកិច្ច ការព្យាករណ៍កំណើនពិតប្រាកដសម្រាប់ឆ្នាំ២០២៣ ត្រូវបានបន្ទាបមកនៅត្រឹម ៥,២ភាគរយ ដោយសារ តាមការព្យាករណ៍ ការធ្លាក់ចុះនៃពាណិជ្ជកម្មសកល ជាពិសេសនៅសហរដ្ឋអាមេរិក និងប្រទេសចិន។ សហរដ្ឋអាមេរិកជាទីផ្សារនាំចេញធំបំផុតរបស់កម្ពុជា ហើយប្រទេសចិនក៏ជាប្រភពធំជាងគេនៃការវិនិយោគផ្ទាល់ពីបរទេសរបស់ខ្លួនដែរ។

ទោះជាយ៉ាងណាក៏ដោយ ទស្សនៈវិស័យរយៈពេលមធ្យមនៅមានភាពវិជ្ជមាន ដោយមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជួយគាំទ្រដល់កំណើននៃផលិតកម្មកសិកម្ម និងការកែច្នៃកសិផល។ ការវិនិយោគខ្លាំងទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធនានានឹងផ្តល់អត្ថប្រយោជន៍ដល់វិស័យជាច្រើន រួមទាំងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចដែលទំនងជានឹងមានសន្ទុះកើនដែមទៀត។[13]

## ២.២. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ២០១២-២០២២

ស្ថិតិនេះបង្ហាញពីចំណែកនៃវិស័យសេដ្ឋកិច្ចក្នុងផលិតផលក្នុងស្រុកសរុប (GDP) នៅកម្ពុជាពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២២។ នៅឆ្នាំ ២០២២ ចំណែកនៃវិស័យកសិកម្មនៅក្នុងផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាមាន ២២.២៣% ឧស្សាហកម្មបានចូលរួមចំណែកប្រមាណ ៣៧.៩% ហើយវិស័យសេវាកម្មបានរួមចំណែកប្រហែល ៣៣,៨៥%។[14]

[12] សារណាបញ្ចប់សារសិក្សានិស្សិតៈ (ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា) ឡៃ បូរ៉ាពីន ទំព័រទី ២០ &២១)

[13] សារណាបញ្ចប់សារសិក្សានិស្សិតៈ (ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា) ឡៃ បូរ៉ាពីន ទំព័រទី ២២ &២៣)

[14] Share of economic sectors in the GDP in Cambodia 2012-2022

ក្រាហ្វិកទី២.១ ៖ បង្ហាញពីការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ឆ្នាំ២០១២-២០២២




ទិន្នន័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរាយការណ៍នៅ ០.២៥៧%ក្នុងឆ្នាំ ២០២២។ នេះកត់ត្រាការថយចុះពីចំនួនមុន ១.១៥៦%សម្រាប់ឆ្នាំ ២០២១។ Cambodia KH: GDP: កំណើន៖ តម្លៃបន្ថែមសរុប ៖ ទិន្នន័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំជាមធ្យម ២.៣៦០%ចាប់ពីខែធ្នូ ឆ្នាំ ១៩៩៤ (មធ្យម) ដល់ឆ្នាំ២០២២ ដោយមានការសង្កេតចំនួន ២៩ ។ ទិន្នន័យបានឈានដល់កម្រិតខ្ពស់គ្រប់ពេលវេលាគឺ ១៥.៧២០% ក្នុង២០០៥ និងទាបបំផុតនៃ -៥៦.៧៧០% ក្នុងឆ្នាំ ១៩៩៤។ Cambodia KH: GDP: កំណើន: តម្លៃបន្ថែមសរុប៖ ទិន្នន័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតែស្ថិតក្នុងស្ថានភាពសកម្មនៅក្នុង CEIC ហើយត្រូវបានរាយការណ៍ដោយធនាគារពិភពលោក។ ទិន្នន័យនេះត្រូវបានចាត់ថ្នាក់នៅក្រោម Global Database's Cambodia – Table KH.World Bank.WDI: ផលិតផលក្នុងស្រុកសរុប៖ អត្រាកំណើនប្រចាំឆ្នាំ។ អត្រាកំណើនប្រចាំឆ្នាំសម្រាប់តម្លៃកសិកម្ម ព្រៃឈើ និងនេសាទត្រូវបានបន្ថែមដោយផ្អែកលើរូបិយប័ណ្ណក្នុងស្រុកថេរ។ សរុបគឺផ្អែកលើតម្លៃថេរឆ្នាំ ២០១៥ដែលបង្ហាញជាដុល្លារអាមេរិក។ កសិកម្មត្រូវគ្នាទៅនឹងផ្នែក ISIC 01-03 ហើយរួមមានព្រៃឈើ ការបរបាញ់ និងការនេសាទ ព្រមទាំងការដាំដុះដំណាំ និងផលិតកម្មបសុសត្វ។ តម្លៃបន្ថែមគឺជាទិន្នផលសុទ្ធនៃវិស័យមួយ បន្ទាប់ពីបូកបញ្ចូលលទ្ធផលទាំងអស់ និងដកធាតុចូលកម្រិតមធ្យម។ វាត្រូវបានគណនាដោយមិនធ្វើការកាត់សម្រាប់រំលោះនៃទ្រព្យសកម្មប្រឌិត ឬការថយចុះ និងការរិចរិលនៃធនធានធម្មជាតិ។ ប្រភពដើមនៃតម្លៃបន្ថែមត្រូវបានកំណត់ដោយចំណាត់ថ្នាក់ឧស្សាហកម្ម

ស្តង់ដារអន្តរជាតិ (ISIC) ការកែប្រែ 4. ទិន្នន័យគណនីជាតិរបស់ធនាគារពិភពលោក និងឯកសារទិន្នន័យគណនីជាតិ OECD ។

ក្រាហ្វិកទី២.២៖ កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម ឆ្នាំ២០១២-២០២១




## ២.២.១. ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម

ក្រសួងបានប្រកាសដាក់ឱ្យប្រើប្រាស់នូវឯកសារ "គោលនយោបាយផ្សព្វផ្សាយ កសិកម្មនៅកម្ពុជា" ដើម្បីឱ្យកសិករនិងសហគមន៍កសិកម្មទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេក វិទ្យាកសិកម្មបានល្អប្រសើរ។ បន្ថែមលើនេះ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពី "ការ ជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ" បរិមាណអង្ករនាំចេញទៅកាន់ទីផ្សារអន្តរជាតិ បានកើនឡើងប្រមាណ ៦២% ក្នុងរយៈពេល៥ឆ្នាំ ចាប់ពី២០១៤ដល់២០១៨ និងអង្ករពូជស្រូវផ្កាម្លិះត្រូវបានចាត់ទុកថាមានគុណភាពល្អ ជាងគេក្នុងពិភពលោក។[15] ការកែប្រែទិសដៅពីការអភិវឌ្ឍតាមបែបទូលាយទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ បានក្លាយជារបៀបវារៈមួយដែលសំខាន់។ ដែលជាកត្តាមួយជួយពង្រឹងសេវាកម្មដ៏មានប្រសិទ្ធភាព ដូចជាការស្រាវជ្រាវ ការផ្សព្វផ្សាយនូវបច្ចេកវិទ្យាដែលទំនើបៗនៅកាន់អនុវិស័យនានាទៅតាមទីតាំងភូមិសាស្ត្រ ការកែប្រែលម្អពូជ ការប្រើប្រាស់ដី និងការផ្តល់ជាឥណទានតាមជនបទ ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង និងជាអាតិភាពរបស់រដ្ឋាភិបាល ដែលសំដៅលើការលើកកម្ពស់ផលិតភាពកសិកម្ម ដែលត្រូវជាមួយនឹងតម្រូវការទីផ្សារទៅតាមស្តង់ដារអន្តរជាតិ ដែលមានទាំងគុណភាព បរិមាណ និងសុវត្ថិភាព។

យើងកត់សម្គាល់បានថា ប្រជាជនកសិករយើងសព្វថ្ងៃកំពុងតែផ្លាស់ប្តូរទម្លាប់ពីការផលិតបម្រើសេចក្តីត្រូវការរបស់ខ្លួនមកជាការផលិតដើម្បីលក់ ពីព្រោះមានចំណូលច្រើន និងមានទីផ្សារផងដែរ។ ដោយយោងតាមការប្រែប្រួលនេះ ទើបយើងសន្និដ្ឋានបានថា សហគមន៍កសិម្មកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់

[15] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ,២០១៩- ២០២៣, ទំព័រទី ១៩

ដែលនាំ ឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គមជនបទកម្ពុជា ជាពិសេសទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងបរិស្ថានល្អ។ ជាការកត់សម្គាល់ កសិករបានចងក្រងគ្នាបង្កើតជាសហគមន៍អភិវឌ្ឍន៍កសិកម្ម ផលិតបន្លែសរីរាង្គ ហើយធ្វើការសម្អាតរួចវេចខ្ចប់ ដើម្បីផ្គត់ផ្គង់ទៅកាន់ទីផ្សារទំនើបផ្សេងៗនៅរាជធានីភ្នំពេញ។ នេះបង្ហាញឱ្យឃើញ ថា កសិករយើងបាននិងកំពុងប្រែក្លាយខ្លួនចេញពី "កសិករ ទៅជាកសិ-ពាណិជ្ជករ" ដើម្បី ទទួលបានតម្លៃបន្ថែមក្នុង ជីវភាពរស់នៅរបស់ខ្លួន។ ក្នុងបរិបទនេះ យើងសង្កេតឃើញថា មានស្ថាប័នជាច្រើន ទាំងរាជរដ្ឋាភិបាល វិស័យឯក ជន និងអង្គការក្រៅរដ្ឋាភិបាលបាន និងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះ ដឹង និងចំណេះធ្វើដល់កសិករនៅ មូលដ្ឋាន។ ម្យ៉ាងវិញទៀតមានកសិករជាច្រើនបានទាញយកបទពិសោធន៍ ជំនាញ និងទេពកោសល្យយកទៅអនុវត្តប្រកបដោយនិងច្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាង ត្រចះត្រចង់នៅក្នុង តំបន់ជាច្រើនទៅតាមអនុវិស័យនីមួយៗ។

បច្ចុប្បន្ននេះយើងឃើញថាការប្រើប្រាស់សម្ភារៈកសិកម្មមានការកើនឡើងដោយស្របទៅតាមស្ថានភាព ការអភិវឌ្ឍផលិតកម្មនៅក្នុងប្រទេស ដែលធ្វើអោយមានការនាំចូលនូវសម្ភារៈកសិកម្ម និងបរិមាណសម្ភារៈ កសិកម្មដែលផលិតលាយផ្សំនៅក្នុងស្រុកមានការកើនឡើង។ ដោយហេតុនេះរដ្ឋាភិបាលបានកំណត់យុទ្ធ សាស្ត្រមិនយកពន្ធ ឬកំណត់បរិមាណពន្ធសូន្យលើការនាំចូលសម្ភារៈកសិកម្ម ក្នុងគោលបំណងបង្កភាពប្រកួត ប្រជែងទីផ្សារនៃផលិតកម្មក្នុងស្រុក ដែលអាចអោយកសិករទិញសម្ភារៈកសិកម្មមានតម្លៃថោក និងប្រកបដោយ គុណភាព។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំពង្រឹងលើការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារ កសិកម្ម ដែលបានចុះបញ្ជីកាត្រឹមត្រូវ ព្រមទាំងពង្រឹងការ ត្រួតពិនិត្យអាជីវកម្មលក់ដុំ និងលក់រាយសម្ភារ កសិកម្មនៅតាមបណ្តារាជធានីខេត្ត ឱ្យបានសមស្របតាមនីតិវិធី និង មានកម្រិតស្តង់ដារច្បាស់លាស់ដើម្បីឱ្យ មានប្រសិទ្ធភាពក្នុងការធ្វើផលិតកម្មកសិកម្ម។

### **២.២.២. កំណើនផលិតផលក្នុងស្រុក GDP ឆ្នាំ ២០២២-២០២៣**

នៅក្នុងឆ្នាំ ២០២២ សេដ្ឋកិច្ចសកលនៅបន្តរក្សាបានកំណើនវិជ្ជមាន ក្នុងអត្រាប្រមាណ ៣,៤% បើ ទោះបីជាទទួលរងផល ប៉ះពាល់ ពីភាពមិនអំណោយផលនៃកត្តាភូមិសាស្ត្រនយោបាយក្តី។ យ៉ាងណាមិញ សន្ទុះកំណើនជារួមមានការថមថយ ដោយសារការផ្ទុះឡើង និងបន្តអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន ដែលធ្វើឱ្យមានការផុសចេញនូវនិន្នាការអវិជ្ជមានមួយ ចំនួន រួមមាន ការកើនឡើងសម្ពាធអតិផរណា ដោយសារ ការកើនឡើងយ៉ាងគំហុកនៃថ្លៃប្រេងអន្តរជាតិ និងទំនិញផ្សេងៗ ព្រមទាំង ការរឹតបន្តឹងយ៉ាងឆាប់ហ័ស និងយូរ ជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុ ដើម្បីឆ្លើយតបការកើនឡើងលឿននៃសម្ពាធ អតិផរណា ដែល បានបន្ទចបង្អាក់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចសកលពីវិបត្តិជំងឺកូវីដ-១៩។ បើទោះបីសេដ្ឋកិច្ចសកល និង

តំបន់ ប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ក្តី សេដ្ឋកិច្ចកម្ពុជាបានបន្តនិន្នាការកើនឡើង ជាមួយនឹងអត្រាកំណើន ៥,២% ក្នុងឆ្នាំ ២០២២ ធៀបនឹង ៣,០% ក្នុងឆ្នាំ ២០២១ ដែលបន្តគាំទ្រដោយតម្រូវការខាងក្រៅ និងទ្រទ្រង់ដល់កំណើនវិស័យឧស្សាហកម្ម (កាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ)។ កំណើនជារួមសម្រាប់ឆ្នាំ ២០២២ នេះ ក៏គាំទ្រផងដែរ ដោយមានការវិលត្រឡប់ទៅរក ភាពប្រក្រតីឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ដែលធ្វើឱ្យវិស័យទេសចរណ៍ និងសេវាកម្មគាំទ្រងើបឡើងវិញលឿនជាងការ រំពឹងទុក។ ចំណែកវិស័យឧស្សាហកម្មបន្តសម្រេចបានកំណើនល្អប្រសើរក្នុងអត្រា ៨,៣% ដោយសារការបន្តរក្សាបាននូវកំណើនរឹងមាំនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាប។ វិស័យសេវាកម្មងើបឡើង វិញក្នុងអត្រាកំណើន ៤,៦% គាំទ្រដោយការងើបឡើងវិញលឿនជាងការរំពឹងទុកនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន។ វិស័យកសិកម្មនៅបន្តរក្សាបានកំណើនវិជ្ជមានក្នុងរង្វង់ ០,៧% បន្តគាំទ្រដោយអនុវិស័យចិញ្ចឹមសត្វ, អនុវិស័យដំណាំ (ដំឡូងមីនិងពោត) និងការងើបឡើងបន្តិចវិញនៃអនុវិស័យនេសាទ។

ក្នុងបរិបទដែលសេដ្ឋកិច្ចកម្ពុជាកំពុងងើបឡើងវិញនេះ ផសស ថ្លៃបច្ចុប្បន្ន បានកើនដល់ ១២០ ៩៨៩ ប៊ីលានរៀល ស្របពេលដែល ផសស សម្រាប់មនុស្សម្នាក់ ស្ថិតក្នុងរង្វង់ ១ ៧៨៤ ដុល្លារអាមេរិក។ ចំពោះអត្រាអតិផរណា ស្ថិតក្នុងកម្រិតគ្រប់គ្រងបាន ក្នុងអត្រា ៥,២% ក្នុងឆ្នាំ ២០២២ ដោយសារការកើនឡើងខ្ពស់នៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត បណ្តាលមកពីការផ្ទុះ ឡើងនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។

ចំពោះសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៣ ត្រូវបានរំពឹងថានឹងបន្តនិន្នាការកើនឡើង ក្នុងអត្រា ៥,៦% ដែលទាបជាង ការរំពឹងទុកបន្តិច ប៉ុន្តែនៅតែជាកំណើនរឹងមាំបើធៀបនឹងបណ្តាប្រទេសក្នុងតំបន់។ កំណើនទាបជាងការរំពឹងទុកបន្តិចនេះ បណ្តាល មកពីការថមថយនៃអនុវិស័យកាត់ដេរ ខណៈដែលអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងសេវាកម្មគាំទ្រផ្សេងទៀត នៅបន្ត និន្នាការល្អប្រសើរ។ សន្ទុះកំណើននៃវិស័យឧស្សាហកម្មរំពឹងថានឹងមានការថមថយ ជាពិសេសអនុវិស័យកាត់ដេរ ដោយសារការ រំពឹងទុកការថមថយនៃតម្រូវការសកល ដែលមួយផ្នែកធំជាបច្ច័យអវិជ្ជមាននៃការកើនឡើងសម្ពាធអតិផរណា និងការរឹតបន្តឹងឆាប់ រហ័ស និងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុ ដែលជាវិបាកនៃសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន។ ចំណែកអនុវិស័យសំណង់បន្តមានកំណើនទាបដោយសារការងើបឡើងវិញយឺតនៃលំហូរវិនិយោគពីបរទេស ខណៈដែលវិស័យនេះនៅបន្តទ្រទ្រង់ដោយសកម្មភាពសំណង់ ជាពិសេសលំនៅឋានថ្លៃទាប និងនិន្នាការថ្មីពោលគឺសកម្មភាពសំណង់បម្រើឱ្យវិស័យ ឧស្សាហកម្ម និងសេវាកម្មក្នុងស្រុក ដូចជារោងចក្រ និងអគារផ្សារទំនើប ជាដើម។ វិស័យសេវាកម្មបន្តកើនឡើង គាំទ្រដោយការបន្តងើបឡើងវិញនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងសេវាកម្មគាំទ្រផ្សេងៗ ហើយនឹងចូលរួមចំណែក យ៉ាងសំខាន់ក្នុងការទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចឆ្នាំ ២០២៣ នេះ។

វិស័យកសិកម្មបន្តនិន្នាការល្អប្រសើរ ដែលបន្តគាំទ្រដោយ អនុវិស័យដំណាំ រួមមានដំណាំស្រូវ និងដំណាំសាកវប្បកម្មរួមផ្សំ, និន្នាការល្អប្រសើរនៃអនុវិស័យចិញ្ចឹមសត្វ ជាពិសេសផលិតកម្ម ជ្រូក និងការបន្តងើបឡើងវិញនៃអនុវិស័យនេសាទ។ ជាការពិតឥទ្ធិពលនៃសង្គ្រាមគួបផ្សំនឹងស្លាកស្នាមដែលសេសសល់ពីវិបត្តិ ជំងឺកូវីដ-១៩ ក៏បន្តបង្កជាផលប៉ះពាល់លើទិដ្ឋភាពសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ជាពិសេសក្រុមប្រជាជនងាយរងគ្រោះ។

ក្រាហ្វិកទី២.៣ ៖ ការវាយតម្លៃ និងព្យាករកំណើនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០២២-២០២៣[16]




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២

## ២.៣. គោលនយោបាយនិង យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍក្នុងវិស័យកសិកម្ម

### ២.៣.១. គោលបំណងយុទ្ធសាស្ត្រ

ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ ក្រសួងបានកំណត់គោលបំណងយុទ្ធសាស្ត្ររួមសម្រាប់អនុវត្តគឺ "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហា- រូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព" ។

វិស័យកសិកម្មដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការអភិវឌ្ឍជនបទ ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

[16] ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ, *ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២*

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម សម្រេចបាន ក្នុងរង្វង់ពី៣%ទៅ៥% ក្នុងមួយឆ្នាំ។ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ការព្យាករនៃកំណើននេះ នឹងត្រូវសម្រេចឱ្យបានក្នុង រង្វង់៤%ក្នុងមួយឆ្នាំ ពោលគឺនឹងត្រូវកើនពី ២១ ៩១៣ពាន់លានរៀលនៅឆ្នាំ២០១៨ ដល់ ២៥ ៧០០ពាន់លានរៀល នៅឆ្នាំ ២០២៣។

### ២.៣.២. គោលដៅយុទ្ធសាស្ត្រ

ដើម្បីអោយគោលដៅយុទ្ធសាស្ត្រមានអាទិភាពយើងត្រូវកំណត់យុទ្ធសាស្ត្រចំនួន០២ គឺ៖

**(ទី១)** បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម

**(ទី២)** បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយ និរន្តរភាព

**គោលដៅយុទ្ធសាស្ត្រទី១៖** ជំរុញផលិតកម្មកសិកម្មតាមលក្ខណៈទំនើប និងយន្តូបនីយកម្មដោយជំនួសឱ្យ ការថយចុះនៃកម្លាំងពលកម្មកសិកម្ម លក្ខណៈសន្សំសំចៃ ធ្វើឱ្យថ្លៃដើមផលិតទាប ធ្វើពិពិធកម្មដំណាំដែលមាន សក្តានុពលសេដ្ឋកិច្ចខ្ពស់ ហើយផ្តល់ប្រាក់ចំណេញច្រើនសម្រាប់កសិករ សហគមន៍កសិកម្ម ដែលនឹងនាំដល់ការប្រកួត ប្រជែងទីផ្សារខ្ពស់ ព្រមទាំងដំណើរការកសិ-ធុរកិច្ចមានលក្ខណៈបរិយាប័ន្ន ប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាព។

**គោលដៅយុទ្ធសាស្ត្រទី២៖** គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ សមត្ថភាពបច្ចេកទេសក្នុងការគ្រប់គ្រងនឹងត្រូវកើនឡើងជាចាំបាច់ ដើម្បីចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច។

### ២.៣.៣. យុទ្ធសាស្ត្រ និងកម្មវិធីការអភិវឌ្ឍន៍វិស័យកសិកម្ម

ដើម្បីជួយជំរុញវិស័យកសិកម្មអោយកាន់តែរីកចម្រើនយើងគួរតែប្រើយុទ្ធសាស្ត្រចំនួន៥ខាងក្រោមនេះ[17]៖

(១) បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិ-ធុរកិច្ច

(២) លើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម

(៣) ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព

(៤) ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព

(៥) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

[17] សៀវភៅ ៖ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម* ២០១៩-២០២៣ ទំព័រ ទី៤០ដល់៤៥។

**កម្មវិធីទី១៖ បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិ-ធុរកិច្ច**

ដើម្បីបង្កើនផលិតភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាន បន្តជំរុញការបង្កើនផលិតភាព គុណភាព និងពិពិធកម្ម តាមរយៈ ការបង្កើនការវិនិយោគប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិលើការស្រាវជ្រាវ និងការអភិវឌ្ឍពូជដំណាំដែល ផ្តល់តម្លៃបន្ថែមខ្ពស់ ជាមួយនឹងបច្ចេកវិទ្យាវៃឆ្លាត ឌីជីថល ទាន់សម័យ និងការផ្សព្វផ្សាយដោយផ្ទាល់ដល់កសិករ នៅទីជនបទដែលខ្វះជំនាញបច្ចេកទេស ការតភ្ជាប់រវាងសហព័ន្ធ ឬ សហគមន៍កសិកម្ម និងវិស័យឯកជនតាមរយៈ យន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពលើការប្រើប្រាស់ទឹក ព្រមជាមួយ នឹងការពង្រីកផ្ទៃដីស្រោចស្រព ព្រមទាំងបន្តជំរុញ និងសម្រប សម្រួលក្នុងការផ្តល់ប័ណ្ណកាន់កាប់កម្មសិទ្ធិដីដល់ កសិករ ក្នុងការរៀបចំយុទ្ធសាស្ត្រទ្រទ្រង់ដល់ការផ្តល់សេវាធានារ៉ាប់រងផលិតកម្មកសិកម្ម ព្រមទាំងការពង្រឹងយន្តការការអនុវត្ត កសិកម្មល្អ និងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម។

**កម្មវិធីទី២៖ លើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម**

ភាពអនុវិស័យសុខសត្វ និងផលិតកម្មសត្វ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការក្នុងវិស័យកសិកម្ម។អនុវិស័យនេះមានយុទ្ធសាស្ត្រអាទិភាពសំខាន់ៗដែលទាក់ទងទៅនឹងការបង្កើនផលិតកម្មសត្វ លើកកម្ពស់សុខភាពសត្វ ការពង្រីកទីផ្សារ សុវត្ថិភាពចំណីអាហារ សុខភាព សាធារណៈ សន្តិសុខស្បៀង និងតួនាទីរបស់វិស័យឯកជន ក្រុមកសិករ/សហគមន៍កសិកម្ម ភ្នាក់ងារសុខភាពសត្វ ភូមិ និងបញ្ហាអន្តរវិស័យមួយចំនួនដែលពាក់ព័ន្ធដល់ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ។

**កម្មវិធីទី៣៖ ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព**

ដើម្បីពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តការយកចិត្តទុកដាក់ទៅលើកំណែទម្រង់អនុវិស័យជលផល ក្នុងគោលដៅបំពេញតម្រូវការសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ បង្កើនប្រាក់ចំណូលប្រជាពលរដ្ឋ និងថែរក្សា ធនធានមច្ឆជាតិឱ្យបានគង់វង្ស តាមរយៈការជំរុញការស្រាវជ្រាវវិទ្យាសាស្ត្រជលផល ការគ្រប់គ្រងសហគមន៍ នេសាទ ការអភិរក្សជលផល ការការពារព្រៃលិចទឹក ការប្រយុទ្ធនឹងការនេសាទខុសច្បាប់ ជំរុញការអភិវឌ្ឍវារី- វប្បកម្ម និងការអភិវឌ្ឍការកែច្នៃ និងគុណភាពផល ផលិតផលជលផល។

**កម្មវិធីទី៤៖ ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព**

ព្រៃឈើជាប្រភពធនធានធម្មជាតិដ៏មានតម្លៃ ចូលរួមលើកកម្ពស់លើផ្នែកសេដ្ឋកិច្ច បរិស្ថាន ទេសចរណ៍ ការសិក្សាស្រាវជ្រាវប្រព័ន្ធការពារទីជម្រាល ប្រព័ន្ធការពារជីវចម្រុះ និងផ្តល់ជម្រកសម្រាប់ស្ថិរភាពនៃជីវិតរស់នៅ

របស់មនុស្ស និងសត្វគ្រប់ប្រភេទ។ ការខិតខំប្រឹងប្រែងដើម្បីរួបរួមគ្នាទប់ស្កាត់គ្រោះមហន្តរាយនៃការបាត់បង់ធនធានព្រៃឈើគឺជាកត្តាចាំបាច់បំផុត ពិសេសការពង្រឹងស្មារតីម្ចាស់ការទទួលខុសត្រូវលើកិច្ចការនេះ។ ការស្តារព្រៃឈើគឺជាគោលដៅសំខាន់ក្នុងការជំរុញឱ្យមានគម្របព្រៃឈើបៃតង ក៏ដូចជាផ្តល់នូវការរីកចម្រើនសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិ និងឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ឈើក្នុងស្រុកដែលកើតមានឡើងកាន់តែខ្លាំង។

**កម្មវិធីទី៥៖ បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងការពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព គឺជាគ្រឹះដ៏រឹងមាំដើម្បីឈានទៅសម្រេចបាននូវគោលដៅគោលនយោបាយដែលបានដាក់ចេញ។

### ២.៣.៤. យុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល គឺចង់លើកស្ទួយវិស័យកសិកម្មដែលក្នុងនោះបាន កំណត់កម្មវិធីអាទិភាពលើកស្ទួយផលិតកម្មសត្វ និងសុខភាពសត្វ និងដាក់ចេញនូវទិសដៅចំនួន៤គឺ៖

ក. ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រលើកកម្ពស់ការចិញ្ចឹមសត្វ។

ខ. ជំរុញការលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍន៍លើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋាន។

គ. ជំរុញអនុម័តបទដ្ឋានក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានក្នុងគោលដៅ ពង្រឹងការអនុវត្តស្តង់ដារអនាម័យសត្វ សាច់ និងផលិតផលសត្វ បង្ការ ទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺ សត្វ និងជំងឺស៊ូណូស ដើម្បីការពារសុខភាពសត្វ សុខុមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។

ឃ. ជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ដើម្បីគាំទ្រដល់ផលិតកម្មចិញ្ចឹមសត្វរួមជាមួយការ លើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន ការលើកទឹកចិត្តវិនិយោគឯកជនក្នុងការកែច្នៃផលិតផលសត្វ ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងមានការសម្រួលពាណិជ្ជកម្មសត្វ និងផលិតផល សត្វ។

## ២.៤. តួនាទីរបស់រដ្ឋាភិបាលក្នុងវិស័យកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នមួយដែលសំខាន់ ដែលមានតួរនាទីទៅលើការអភិវឌ្ឍវិស័យកសិកម្មទាំងមូលនៅប្រទេសកម្ពុជា។ នៅបណ្តានាយកដ្ឋានកសិកម្ម និងកម្មវិធីនានា ដែលស្ថិតនៅក្រោមក្រសួងនេះបានផ្តោតសំខាន់ទៅលើ ការអភិវឌ្ឍដំណាំ អភិវឌ្ឍន៏ការចិញ្ចឹមសត្វ ដែលជម្រុញអោយមានការកែលម្អបច្ចេកទេសផលិតផលកសិកម្ម ការស្រាវជ្រាវនិងការអប់រំ ការផ្សព្វផ្សាយនិងសេវាបច្ចេកទេស។

បណ្ដាក្រសួង និងភ្នាក់ងារសារធារណៈនានា ក៏មានតួរនាទីនៅក្នុងវិស័យកសិម្មផងដែរ ដែលអាណត្តិរបស់ខ្លួន បំពេញគ្នា និងការទទួលខុសត្រូវដែលទាក់ទងនឹងវិស័យកសិកម្មដូចជា៖

- ក្រសួងអភិវឌ្ឍន៍ជនបទ គឺទទួលខុសត្រូវលើការអភិវឌ្ឍន៍ដំណាំ ការស្តារផ្លូវលំឡើងវិញ ការគ្រប់គ្រង ធនធានទឹក ការស្រាវជ្រាវ និងការផ្សព្វផ្សាយ
- ក្រសួងបរិស្ថាន គឺត្រូវការពារ និងគ្រប់គ្រងតំបន់បរិស្ថានវាយតម្លៃ និងការបន្ធូរបន្ថយ សក្តានុពលភាពនៃ ផលប៉ះពាល់ដល់បរិស្ថាន
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទទួលបន្ទុកគ្រប់គ្រងដីធ្លី ការវាស់វែងចេញប័ណ្ណកម្មសិទ្ធិ
- ក្រសួងធនធានទឹក និងឧតុនិយម គឺគ្រប់គ្រងធនធានទឹក ដោយរួមបញ្ចូលទាំងប្រព័ន្ធស្រោចស្រព
- ក្រសួងពាណិជ្ជកម្ម មានតួនាទីជំរុញ និងគាំទ្រ ម៉ាឃីធីង ជំនួញ និងការនាំចេញ
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជួយជំរុញទៅដល់ផលិតកម្មស្បៀងអាហារលក្ខណៈគ្រួសារ
- វិទ្យាស្ថានកម្ពុជាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម ធ្វើការអភិវឌ្ឍពូជស្រូវថ្មីៗ និងពង្រីកពូជស្រូវ។

### ២.៤.១. តួនាទីរបស់អង្គការនៅក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាល គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ ហើយបង្កើតឡើងដើម្បី បម្រើផល ប្រយោជន៍សាធារណៈ។ អង្គការក្រៅរដ្ឋាភិបាល ជាច្រើនបានបំពេញតួនាទីយ៉ាង សំខាន់ក្នុងសង្គម ដោយធ្វើ សកម្មភាពមួយចំនួនដែលរាជរដ្ឋាភិបាល និងអង្គភាពឯកជនមួយ ចំនួនមិនអាចធ្វើទៅបាន។ ទោះបីជាការងារ របស់អង្គការក្រៅរដ្ឋាភិបាល មានសារៈសំខាន់ក៏ដោយក៏អង្គការទាំងនេះ នឹងអាចបន្តសកម្មភាពរបស់ខ្លួនបាន លុះត្រាណាតែ អង្គការនេះចាត់ចែង ការងារបានល្អ ហើយផ្តល់សេវាកម្មចាំបាច់ដែលបម្រើផលប្រយោជន៍ សាធារណៈ។

- អង្គការក្រៅរដ្ឋាភិបាល ជាស្ថាប័នអភិវឌ្ឍន៍មួយអាចចូលរួមវិភាគទានយ៉ាងច្រើន ចំពោះ ផែនការកាត់ បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។
- កិច្ចការប្រចាំថ្ងៃរបស់អង្គការក្រៅរដ្ឋាភិបាល គឺធ្វើការយ៉ាងជិតស្និតជាមួយអ្នកក្រីក្រ និង ក្រុមជនងាយរង គ្រោះ។
- អង្គការក្រៅរដ្ឋាភិបាល ក៏មានទំនាក់ទំនងជិតស្និតជាមួយ បណ្តាក្រសួងក្នុងផ្នែកជាច្រើន ដើម្បីដោះ ស្រាយនូវរាលបញ្ហាដែលជួបប្រទះរហូតឈានដល់ការអភិវឌ្ឍ។

### ២.៤.២. តួនាទីរបស់ប្រជាជនកសិករនៅក្នុងវិស័យកសិកម្ម

ប្រជាជនកសិករ ដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យកសិកម្មនៃប្រព័ន្ធផលិតកម្មស្បៀង និងរួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ច បរិស្ថាន និងសង្គម។ ទំនួលខុសត្រូវ និងការរួមចំណែករបស់ពួកគាត់មានវិមាត្រផ្សេងៗគ្នា៖

**ក. ផលិតកម្មអាហារ**

ប្រជាជនកសិករមានទំនួលខុសត្រូវជាចម្បងលើការដាំដុះដំណាំ និងការចិញ្ចឹមសត្វ ដើម្បីផ្គត់ផ្គង់អាហារសម្រាប់មនុស្ស។ នេះពាក់ព័ន្ធនឹងការជ្រើសរើសដំណាំ និងពូជសត្វដែលសមស្រប ការរៀបចំដី ការដាំដុះ ការគ្រប់គ្រងសត្វល្អិត និងជំងឺ ការស្រោចស្រព ការប្រមូលផល និងការធានាគុណភាព និងសុវត្ថិភាពនៃអាហារដែលបានផលិត។

**ខ. ការរួមចំណែកសេដ្ឋកិច្ច**

ប្រជាជនកសិកម្ម គឺជាវិស័យសេដ្ឋកិច្ចដ៏សំខាន់នៅក្នុងប្រទេសជាច្រើន ហើយកសិកររួមចំណែកដល់សេដ្ឋកិច្ចតាមរយៈ៖

- **ការបង្កើតការងារ៖** កសិកម្មបង្កើតឱកាសការងារដោយផ្ទាល់សម្រាប់មនុស្សរាប់លាននាក់នៅទូទាំងពិភពលោក រួមទាំងកម្មករកសិដ្ឋាន អ្នកជំនាញកសិកម្ម និងតួនាទីគាំទ្រផ្សេងៗ។
- **ការបង្កើតប្រាក់ចំណូល៖** កសិករបង្កើតប្រាក់ចំណូលសម្រាប់ខ្លួនឯង និងសហគមន៍របស់ពួកគេតាមរយៈការលក់ផលិតផលកសិកម្ម។
- **ការចូលរួមទីផ្សារ៖** កសិករចូលរួមក្នុងទីផ្សារក្នុងស្រុក ជាតិ និងពិភពលោក ដែលមានឥទ្ធិពលលើសមតុល្យពាណិជ្ជកម្ម និងរួមចំណែកដល់ស្ថិរភាពសេដ្ឋកិច្ច។

**គ. និរន្តរភាព និងការគ្រប់គ្រងបរិស្ថាន**

ប្រជាជនកសិករ ដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងលើកកម្ពស់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព៖

- **សុខភាពដី៖** អនុវត្តការបង្វិលដំណាំ គម្របដំណាំ និងការធ្វើកសិកម្មសរីរាង្គ ដើម្បីរក្សា និងកែលម្អជីជាតិដី។
- **ការគ្រប់គ្រងទឹក៖** ការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព តាមរយៈបច្ចេកទេសដូចជាប្រព័ន្ធធារាសាស្ត្រតំណក់ និងការប្រមូលផលទឹកភ្លៀង ដើម្បីធានាបាននូវនិរន្តរភាព។
- **ជីវៈចម្រុះ៖** ការអភិរក្ស និងលើកកម្ពស់ជីវៈចម្រុះ ដោយការថែរក្សាពូជដំណាំចម្រុះ និងពូជបសុសត្វ និងការអនុវត្តការគ្រប់គ្រងសត្វល្អិតរួមបញ្ចូលគ្នា។

- **ការបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ៖** ការទទួលយកការអនុវត្តដូចជា ការរុះរើបែបអភិរក្ស រុក្ខកម្មកសិកម្ម និងការប្រមូលកាបូន ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

**ឃ. ការទទួលយកការច្នៃប្រឌិត និងបច្ចេកវិទ្យា**

ប្រជាជនកសិករ រួមចំណែកលើកកម្ពស់វិស័យកសិកម្មដោយ៖

- **បច្ចេកវិទ្យាទទួលយក៖** ការប្រើប្រាស់បច្ចេកវិជ្ជាទំនើបៗ ដូចជាការធ្វើកសិកម្មច្បាស់លាស់ យន្តហោះគ្មានមនុស្សបើក និងបច្ចេកវិទ្យាជីវសាស្ត្រ ដើម្បីបង្កើនផលិតភាព ប្រសិទ្ធភាព និងនិរន្តរភាព។
- **ស្រាវជ្រាវ និងអភិវឌ្ឍន៍៖** ចូលរួមក្នុងការសាកល្បងស្រាវជ្រាវ និងទទួលយកបច្ចេកទេសកសិកម្មថ្មី និងពូជដំណាំដែលបង្កើតឡើងដោយអ្នកវិទ្យាសាស្ត្រកសិកម្ម។

## ២.៥. ឱកាសសម្រាប់ការវិនិយោគតាមរយៈវិស័យកសិកម្ម

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ លើកទឹកចិត្ត គាំទ្រ និងជួយសម្របសម្រួលជាមួយក្រសួង ពាក់ព័ន្ធ ប្រទេសបញ្ជាទិញ ដើម្បីអន្តរាគមន៍បានចូលទីផ្សារក្នុងការប្រកួតប្រជែងផលិតផលរបស់ខ្លួន។ ជាពិសេសបាន រៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្ត នីតិវិធីក្នុងការផ្ដល់សេវា និងបច្ចេកទេសបានឆាប់រហ័សដល់អ្នកវិនិយោគ។ វិស័យកសិកម្មរបស់កម្ពុជាបង្ហាញពីឱកាសជាច្រើនសម្រាប់ការវិនិយោគនាពេលអនាគត ដែលជំរុញដោយធនធានធម្មជាតិដ៏សម្បូរបែប អាកាសធាតុអំណោយផល និងទីតាំងយុទ្ធសាស្ត្រ។ ការវិនិយោគលើវិស័យកសិកម្មអាចបង្កើនផលិតភាព និរន្តរភាព និងកំណើនសេដ្ឋកិច្ចយ៉ាងសំខាន់។ នេះគឺជាផ្នែកសំខាន់ៗមួយចំនួនសម្រាប់ការវិនិយោគសក្ដានុពល៖

**ក. ការកែច្នៃកសិផល និងការបន្ថែមតម្លៃ**

**សក្ដានុពលនៃការវិនិយោគ៖** ការអភិវឌ្ឍគ្រឿងបរិក្ខារកែច្នៃកសិផលអាចបន្ថែមតម្លៃដល់ផលិតផលកសិកម្មឆៅ ពង្រីកអាយុកាលធ្នើ និងបង្កើនលទ្ធភាពទីផ្សារ។ នេះអាចរួមបញ្ចូលការកែច្នៃអង្ករ ដំឡូងមី ផ្លែឈើ បន្លែ និងផលិតផលបសុសត្វ។

- **ឱកាស៖**
  - ✓ បង្កើតរោងម៉ាស៊ីនកិនស្រូវ និងវេចខ្ចប់។
  - ✓ ការបង្កើតអង្គភាពកែច្នៃម្សៅ និងម្សៅដំឡូងមី។
  - ✓ អភិវឌ្ឍកន្លែងដាក់បន្លែ និងផ្លែឈើ សម្ងួត និងទឹកផ្លែឈើ។
  - ✓ បង្កើតរោងចក្រកែច្នៃសាច់ និងផលិតទឹកដោះគោ។

### ខ. ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព

**សក្តានុពលនៃការវិនិយោគ៖** ការលើកកម្ពស់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាពអាចបង្កើនផលិភាព ខណៈពេលដែលការរក្សាបរិស្ថាន។ ការវិនិយោគអាចផ្តោតលើកសិកម្មសរីរាង្គ កសិកម្មអភិរក្ស និងកសិផល។

- **ឱកាស៖**
  - ✓ គាំទ្រកម្មវិធីបញ្ជាក់សរីរាង្គ។
  - ✓ ការវិនិយោគលើការបណ្តុះបណ្តាល និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់កសិកម្មអភិរក្ស។
  - ✓ បង្កើតប្រព័ន្ធកសិរុក្ខាប្រមាញ់ រួមផ្សំដំណាំ និងដើមឈើ។

### គ. បច្ចេកវិទ្យាកសិកម្មទំនើប

សក្តានុពលនៃការវិនិយោគ៖ ការទទួលយកបច្ចេកវិទ្យាទំនើបអាចធ្វើបដិវត្តន៍កសិកម្មកម្ពុជា បង្កើនប្រសិទ្ធភាព និងទិន្នផល។ នេះរួមបញ្ចូលទាំងការធ្វើកសិកម្មច្បាស់លាស់ ជីវបច្ចេកវិទ្យា និងកសិកម្មឌីជីថល។

- **ឱកាស៖**
  - ✓ ការអនុវត្តឧបករណ៍កសិកម្មដែលមានភាពជាក់លាក់ដូចជាឧបករណ៍ដែលណែនាំដោយ GPS និងយន្តហោះគ្មានមនុស្សបើក។
  - ✓ វិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជដំណាំដែលធន់នឹងសត្វល្អិត ផ្តល់ទិន្នផលខ្ពស់
  - ✓ បង្កើតកម្មវិធីទូរស័ព្ទ និងវេទិកាសម្រាប់កសិករដើម្បីចូលប្រើព័ត៌មានទីផ្សារ ការព្យាករណ៍អាកាសធាតុ និងសេវាកម្មប្រឹក្សា។

### ឃ. ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក

សក្តានុពលនៃការវិនិយោគ៖ ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រអាចកាត់បន្ថយផលប៉ះពាល់នៃទឹកភ្លៀងដែលខុសប្រក្រតី និងបង្កើនផលិតភាពដំណាំ។ ប្រព័ន្ធគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាពគឺមានសារៈសំខាន់សម្រាប់វិស័យកសិកម្មប្រកបដោយនិរន្តរភាព។

- **ឱកាស៖**
  - ✓ សាងសង់ និងកែលម្អប្រព័ន្ធប្រឡាយ និងប្រព័ន្ធធារាសាស្ត្រ។
  - ✓ ការអភិវឌ្ឍបច្ចេកវិទ្យាប្រព័ន្ធធារាសាស្ត្រ drip និង sprinkler ។
  - ✓ ការវិនិយោគលើការប្រមូលផល និងដំណោះស្រាយស្តុកទឹក។

**ខ. ការអភិវឌ្ឍន៍បសុសត្វ និងវារីវប្បកម្ម**

**សក្តានុពលនៃការវិនិយោគ៖** ការពង្រីក និងធ្វើទំនើបកម្មវិស័យបសុសត្វ និងវារីវប្បកម្ម អាចបំពេញតម្រូវការកើនឡើងនៃប្រូតេអ៊ីនសត្វ និងរួមចំណែកដល់សន្តិសុខស្បៀង និងសក្តានុពលនាំចេញ។

- **ឱកាស៖**
  - ✓ បង្កើតកសិដ្ឋានចិញ្ចឹមមាន់ ជ្រូក និងគោក្របី ដែលមានសម្ភារៈទំនើបៗ។
  - ✓ អភិវឌ្ឍកសិដ្ឋានចិញ្ចឹមត្រី និងបង្គា ដោយប្រើការអនុវត្តន៍វារីវប្បកម្មប្រកបដោយនិរន្តរភាព។
  - ✓ ការវិនិយោគលើរោងចក្រផលិតចំណីសត្វ និងសេវាសុខភាពសត្វ។

**ច. ខ្សែសង្វាក់ផ្គត់ផ្គង់ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ**

**សក្តានុពលនៃការវិនិយោគ៖** ការកែលម្អប្រព័ន្ធផ្គត់ផ្គង់សង្វាក់ផ្គត់ផ្គង់ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារអាចកាត់បន្ថយការខាតបង់ក្រោយការប្រមូលផល និងបង្កើនលទ្ធភាពទទួលបានទីផ្សារសម្រាប់កសិករ។

- **ឱកាស៖**
  - ✓ ការសាងសង់កន្លែងផ្ទុកត្រជាក់ និងឃ្លាំង។
  - ✓ អភិវឌ្ឍបណ្តាញដឹកជញ្ជូន និងចែកចាយប្រកបដោយប្រសិទ្ធភាព។
  - ✓ ការបង្កើតទីផ្សារលក់ដុំ និងមជ្ឈមណ្ឌលប្រមូលផ្តុំ។

**ឆ. សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង**

**សក្តានុពលនៃការវិនិយោគ៖** ការពង្រីកសេវាកម្មហិរញ្ញវត្ថុ និងផលិតផលធានារ៉ាប់រងដែលតម្រូវសម្រាប់វិស័យកសិកម្មអាចផ្តល់ឱ្យកសិករនូវលទ្ធភាពទទួលបានឥណទាន និងឧបករណ៍គ្រប់គ្រងហានិភ័យ។

- **ឱកាស៖**
  - ✓ អភិវឌ្ឍគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្តល់ប្រាក់កម្ចីក្នុងតម្លៃសមរម្យដល់កសិករខ្នាតតូច។
  - ✓ ណែនាំផលិតផលធានារ៉ាប់រងដំណាំ និងបសុសត្វ។
  - ✓ បង្កើតកម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដើម្បីអប់រំកសិករលើការគ្រប់គ្រងហិរញ្ញវត្ថុ និងការវិនិយោគ។

**ជ. ស្រាវជ្រាវ និងអភិវឌ្ឍន៍** (R&D)

សក្តានុពលនៃការវិនិយោគ៖ ការវិនិយោគលើការស្រាវជ្រាវ និងការអភិវឌ្ឍន៍កសិកម្មអាចជំរុញការបង្កើតថ្មី និងដោះស្រាយបញ្ហាប្រឈមនានាទាក់ទងនឹងផលិតកម្មដំណាំ និងបសុសត្វ។

- **ឱកាស៖**
  - ✓ ការបង្កើតវិទ្យាស្ថានស្រាវជ្រាវកសិកម្ម និងភាពជាដៃគូជាមួយសាកលវិទ្យាល័យ។

- ✓ ផ្តល់មូលនិធិស្រាវជ្រាវលើដំណាំដែលធន់នឹងអាកាសធាតុ និងការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព។
- ✓ គាំទ្រសេវាកម្មផ្នែកបន្ថែម ដើម្បីផ្សព្វផ្សាយការរកឃើញ R&D ដល់កសិករ។

**ឈ. ទេសចរណ៍កសិ-ទេសចរណ៍ និងអេកូទេសចរណ៍**

សក្តានុពលនៃការវិនិយោគ៖ ការអភិវឌ្ឍន៍កសិ-ទេសចរណ៍ និងទេសចរណ៍ធម្មជាតិអាចបង្វែរប្រភពចំណូលសម្រាប់សហគមន៍ជនបទ និងលើកកម្ពស់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព។

- ➢ **ឱកាស៖**
  - ✓ បង្កើតបទពិសោធន៍ស្នាក់នៅកសិដ្ឋាន និងដំណើរទេសចរណ៍អប់រំនៅលើកសិដ្ឋានសរីរាង្គ។
  - ✓ បង្កើតគម្រោងទេសចរណ៍ធម្មជាតិ ដែលបង្ហាញពីការខិតខំប្រឹងប្រែងធ្វើកសិកម្ម និងអភិរក្សប្រកបដោយនិរន្តរភាព។
  - ✓ ការបង្កើតមជ្ឈមណ្ឌលកសិទេសចរណ៍បង្ហាញពីទំនៀមទម្លាប់កសិកម្មប្រពៃណីនិងវប្បធម៌ខ្មែរ។

**ញ. ភាពជាដៃគូសាធារណៈ និងឯកជន** (PPPs)

**សក្តានុពលនៃការវិនិយោគ៖** ការសហការជាមួយរដ្ឋាភិបាលតាមរយៈភាពជាដៃគូសាធារណៈ និងឯកជនអាចជំរុញគម្រោងអភិវឌ្ឍន៍កសិកម្មខ្នាតធំ និងកំណែទម្រង់គោលនយោបាយ។

- ➢ **ឱកាស៖**
  - ✓ ភាពជាដៃគូលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដូចជា ប្រព័ន្ធធារាសាស្ត្រ និងផ្លូវជនបទ។
  - ✓ សហការលើគំនិតផ្តួចផ្តើមដើម្បីកែលម្អការអប់រំ និងបណ្តុះបណ្តាលកសិកម្ម។
  - ✓ ចូលរួមក្នុងកិច្ចសន្ទនាគោលនយោបាយ ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់អាជីវកម្មកសិឧស្សាហកម្ម។

ដូច្នេះ វិស័យកសិកម្មរបស់កម្ពុជាផ្តល់ឱកាសវិនិយោគចម្រុះដែលអាចជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់ជីវភាពរស់នៅ និងធានាបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ដោយផ្តោតលើការបន្ថែមតម្លៃ ការអនុវត្តប្រកបដោយនិរន្តរភាព បច្ចេកវិទ្យាជឿនលឿន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សេវាហិរញ្ញវត្ថុ និងភាពជាដៃគូសាធារណៈ និងឯកជន អ្នកវិនិយោគអាចដើរតួយ៉ាងសំខាន់ក្នុងការប្រែក្លាយវិស័យកសិកម្មកម្ពុជា និងបើកសក្តានុពលពេញលេញរបស់ខ្លួន។

## ២.៦ ការប្រៀបធៀបបែបផែនផលិតកម្មតាមប្រភេទសត្វ ក្នុងឆ្នាំ ២០១៩-២០២៣

គោលដៅសម្រាប់ការធ្វើពាណិជ្ជកម្មសត្វគឺ ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ១៣លានក្បាល ក្នុងឆ្នាំ២០១៩ កើនដល់ចំនួន២៧,៤៤លានក្បាល នៅឆ្នាំ២០២២។ ដោយឡែកក្នុងឆ្នាំ ២០១៩ នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានអត្រាកំណើនចំនួន៣០% កើនដល់ ៤១,២%។ អត្រានៃកំណើននេះបានឆ្លុះបញ្ចាំង ឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែល្អប្រសើរឡើង។

### ២.៦.១. ការប្រៀបធៀបបែបផែនផលិតកម្មសត្វសរុប

ចំពោះអត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន៣០% ក្នុងឆ្នាំ២០១៩ ដល់ចំនួន ៤១,២% នៅឆ្នាំ២០២៣។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះពី ចំនួន៧០% ក្នុងឆ្នាំ ២០១៩ មកត្រឹមចំនួន៥៨,៨% នៅឆ្នាំ២០២៣។

ក្រាហ្វិកទី២.៤៖ ប្រៀបធៀបបែបផែនផលិតកម្មសត្វសរុប ពីឆ្នាំ២០១៩-២០២៣



ក្រាហ្វិកទី២.៥៖ ប្រៀបធៀបអត្រានៃបែបផែនផលិតកម្មសត្វសរុប ពីឆ្នាំ ២០១៩-២០២៣




- ក្នុង៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វសរុបមានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺកើន ៨,៦%/ឆ្នាំ ក្នុងនោះ
  - ផលិតកម្មសត្វ លក្ខណៈគ្រួសារ មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺកើន ២,៨%/ ឆ្នាំ
  - ផលិតកម្មសត្វ លក្ខណៈពាណិជ្ជកម្ម មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺកើន ២៣, 0%/ ឆ្នាំ។
- សម្រាប់ឆ្នាំ២០២៣នេះ ធៀបនឹងឆ្នាំ២០២២ ផលិតកម្មសត្វសរុបមានអត្រាកំណើន ២,១% ក្នុងនោះ
  - ផលិតកម្មសត្វ លក្ខណៈគ្រួសារ មានអត្រាកំណើត ១,៣%
  - ផលិតកម្មសត្វ លក្ខណៈពាណិជ្ជកម្ម មានអត្រាកំណើន ៣,៣%។
- បែបផែនផលិតកម្មសត្វ មានអត្រា កើន/ថយ (+/-) 0, ៥%
  - អត្រានៃការចិញ្ចឹមសត្វ លក្ខណៈគ្រួសារ បានថយពី៥៩,៣% ក្នុងឆ្នាំ២០២២ មក ៥៨,៨% នៅឆ្នាំ ២០២៣
  - អត្រានៃការចិញ្ចឹមសត្វ លក្ខណៈពាណិជ្ជកម្ម បានកើនពី៤០,៧% ក្នុងឆ្នាំ២០២២ ដល់ ៤១,២% នៅឆ្នាំ២០២៣។
- ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម ក្នុងឆ្នាំ២០២៣

១. កសិដ្ឋានសរុប កើន ៣០កន្លែង= ២,១% (កើនពី ១ ៤១៨កន្លែង/២០២២ ដល់ ១ ៤៤៨កន្លែង/ ២០២៣) ក្នុងនោះ៖

- កសិដ្ឋានគោ-ក្របី កើន ១៩កន្លែង= ២៦,៤% (កើនពី ៧២កន្លែង/២០២២ ដល់ ៩១កន្លែង/ ២០២៣)

- កសិដ្ឋានជ្រូក កើន ៨កន្លែង= ១,៣% (កើនពី ៦០៦កន្លែង/២០២២ ដល់ ៦១៤កន្លែង/២០២៣)
- កសិដ្ឋានបក្សី កើន ១កន្លែង= ០,១% (កើនពី ៧៣០កន្លែង/២០២២ ដល់ ៧៣១កន្លែង/២០២៣)
- កសិដ្ឋានផ្សេងៗ កើន ២កន្លែង= ២០,០% (កើនពី ១០កន្លែង/២០២២ ដល់ ១២កន្លែង/២០២៣)

២. ស្ថិតិសត្វសរុប កើន ៣, ៣% (កើនពី ២៦,៥៦លានក្បាល/២០២២ ដល់ ២៧,៤៤លានក្បាល/ ២០២៣) ក្នុងនោះ៖

- គោ-ក្របី កើន ១១៩, ៣% (កើនពី ១៦ពាន់ក្បាល ក្នុងឆ្នាំ២០២២ ដល់ ៣៥ពាន់ក្បាល នៅឆ្នាំ ២០២៣)
- ជ្រូក កើន ៦,០% (កើនពី ២,២១លានក្បាល ក្នុងឆ្នាំ២០២២ ដល់ ២,៣៤លានក្បាល នៅឆ្នាំ ២០២៣) បក្សី
- កើន ៣,០% (កើនពី ២៤,២៤លានក្បាល ក្នុងឆ្នាំ២០២២ ដល់ ២៤,៩៦លានក្បាល នៅឆ្នាំ ២០២៣

តារាងទី២.១៖ កសិដ្ឋានចិញ្ចឹមសត្វ លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣

| កសិដ្ឋានចិញ្ចឹមសត្វ លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២ដល់២០២៣ | | | | | ប្រៀបធៀប | | | |
|---|---|---|---|---|---|---|---|---|
| កសិដ្ឋានចិញ្ចឹមសត្វ | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | | ប្រៀបធៀប (+/-) | | ភាគរយ(%) | |
| | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន | ចំនួនសត្វ |
| គោ-ក្របី | 72 | 16 | 91 | 35 | 19 | 19 | 26.4% | 119.3% |
| ជ្រូក | 606 | 2,211 | 614 | 2,345 | 8 | 134 | 1.3% | 6.0% |
| បក្សី | 730 | 24,240 | 731 | 24,961 | 1 | 720 | 0.1% | 3.0% |
| ផ្សេងៗ | 10 | 93 | 12 | 102 | 2 | 9 | 20.0% | 9.6% |
| សរុប | 1,418 | 26,560 | 1,448 | 27,442 | 30 | 882 | 2.1% | 3.3% |

ក្រាហ្វិកទី២.៦៖ កសិដ្ឋានចិញ្ចឹមសត្វ លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣



តារាងទី២.២៖ ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វតាមចំណាត់ថ្នាក់ខ្នាត ប្រចាំឆ្នាំ២០២៣

**ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វតាមចំណាត់ថ្នាក់ខ្នាតប្រចាំឆ្នាំ២០២៣**

| ល.រ | ប្រភេទសត្វ | ខ្នាតតូច | | ខ្នាតមធ្យម | | ខ្នាតធំ | | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនកសិដ្ឋាន | ចំនួនសត្វ | ចំនួនកសិដ្ឋាន | ចំនួនសត្វ | ចំនួនកសិដ្ឋាន | ចំនួនសត្វ | ចំនួនកសិដ្ឋាន | ចំនួនសត្វ |
| 1 | គោសាច់ | 70 | 10,607 | 12 | 5,169 | 4 | 17,760 | 86 | 33,536 |
| 2 | ក្របីសាច់ | 1 | 100 | 0 | 0 | 0 | 0 | 1 | 100 |
| 3 | គោទឹកដោះ | 3 | 272 | 0 | 0 | 1 | 930 | 4 | 1,202 |
| 4 | សេះ | 1 | 25 | 1 | 15 | 0 | 0 | 2 | 40 |
| 5 | ចៀម | 1 | 1,000 | 1 | 1,250 | 0 | 0 | 2 | 2,250 |
| 6 | ពពែ | 3 | 1,370 | 0 | 0 | 0 | 0 | 3 | 1,370 |
| 7 | ជ្រូកសាច់ | 186 | 185,543 | 274 | 899,809 | 60 | 800,857 | 520 | 1,886,209 |
| 8 | ជ្រូកពូជ | 17 | 24,455 | 23 | 45,179 | 54 | 388,810 | 94 | 458,444 |
| 9 | ស្វា | 1 | 174 | 0 | 0 | 3 | 97,502 | 4 | 97,676 |
| 10 | ទន្សាយ | 1 | 900 | 0 | 0 | 0 | 0 | 1 | 900 |
| 11 | មាន់សាច់ | 527 | 12,907,600 | 48 | 3,605,000 | 36 | 6,434,400 | 611 | 22,947,000 |
| 12 | មាន់ស៊ុត | 32 | 305,407 | 4 | 130,700 | 2 | 120,000 | 38 | 556,107 |
| 13 | មាន់ពូជ | 5 | 7,750 | 1 | 12,000 | 5 | 598,000 | 11 | 617,750 |
| 14 | ទាសាច់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 15 | ទាស៊ុត | 64 | 671,790 | 5 | 118,000 | 0 | 0 | 69 | 789,790 |
| 16 | ក្រួច | 1 | 10,000 | 1 | 40,000 | 0 | 0 | 2 | 50,000 |
| សរុប | | 913 | 14,126,993 | 370 | 4,857,122 | 165 | 8,458,259 | 1,448 | 27,442374 |
| ឆ្នាំ២០២២ | | 932 | 15,755,146 | 351 | 3,781,042 | 135 | 7,024,285 | 1,418 | 26,560,473 |
| ប្រៀបធៀប | កើន/ថយ | -19 | -1,628,153 | 19 | 1,076,080 | 30 | 1,433,974 | 30 | 881,901 |
| | ភាគរយ | -2.0% | -10.3% | 5.4% | 28.5% | 22.2% | 20.4% | 2.1% | 3.3% |

## ២.៦.២. ការប្រៀបធៀបផលិតកម្មគោ និងក្របី

បែបផែនផលិតកម្មគោនិង ក្របីលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០១៩ មានចំនួន៣,២២៧,១៤៧ក្បាលស្មើនិង០,៣% ហើយក្នុង២០២០វិញមានចំនួន ៣,២៥៨,៩៧៤ក្បាលស្មើនិង ចំពោះក្នុងឆ្នាំ២០២១វិញយើងឃើញថាមានចំនួន៣,៣៩៩,៩៥៧ក្បាលដែលស្មើនិង០,៤% រីឯក្នុងឆ្នាំ២០២២ មានចំនួន៣,៤៥៨,៥៦៧ក្បាលស្មើនិង០,៥% ចំណែកឯក្នុងឆ្នាំ២០២៣វិញមាន៣,៤៥១,៥៧៥ក្បាលស្មើនិង១%។ ចំពោះផលិតកម្មគោនិង ក្របីលក្ខណៈគ្រួសារក្នុងឆ្នាំ២០១៩ មានចំនួន ១០,០៩៥ក្បាល ហើយក្នុង២០២០វិញមានចំនួន ១៣,៤២៧ក្បាល ចំពោះក្នុងឆ្នាំ២០២១វិញយើងឃើញថាមានចំនួន១៤,៧៩៧ក្បាល រីឯក្នុងឆ្នាំ២០២២ មានចំនួន១៥,៨៨៤ក្បាល និងឆ្នាំ២០២៣មានចំនួន៣៤,៨៣៨ក្បាល។

ចំពោះក្នុងឆ្នាំ២០២៣ បើយើងធៀបទៅនឹងឆ្នាំ២០២២ ផលិតកម្មគោ-ក្របីសរុបមានអត្រាកំណើន ០,៣% ក្នុងនោះមាន៖

- ផលិតកម្មគោ-ក្របី លក្ខណៈគ្រួសារ មានអត្រាថយចុះ ០,២%
- ផលិតកម្មគោ-ក្របី លក្ខណៈពាណិជ្ជកម្ម មានអត្រាកំណើន ១១៩,៣%។

បែបផែនផលិតកម្មគោ-ក្របី៖

- អត្រានៃការចិញ្ចឹមគោ-ក្របី លក្ខណៈគ្រួសារ បានថយពី ៩៩,៥% ក្នុង២០២២ មក ៩៩,០% នៅឆ្នាំ ២០២៣
- អត្រានៃការចិញ្ចឹមគោ-ក្របី លក្ខណៈពាណិជ្ជកម្ម បានកើនពី ០,៥% ក្នុង២០២២ ដល់ ១,០% នៅឆ្នាំ ២០២៣



ក្រាហ្វិកទី២.៧៖ ប្រៀបធៀបបែបផែនផលិតកម្មគោ-ក្របី ពីឆ្នាំ២០១៩-២០២៣



ក្រាហ្វិកទី២.៨៖ ប្រៀបធៀបអត្រានៃបែបផែនផលិតកម្មគោ-ក្របី ពីឆ្នាំ២០១៩-២០២៣




កសិដ្ឋានចិញ្ចឹមគោ-ក្របី លក្ខណៈពាណិជ្ជកម្ម៖

- ផលិតកម្មគោ-ក្របី លក្ខណៈពាណិជ្ជកម្ម ក្នុងឆ្នាំ ២០២៣

១. កសិដ្ឋានចិញ្ចឹមគោ-ក្របីសរុបកើន ១៩កន្លែង ស្មើនឹង ២៦,៤% ក្នុងនោះ៖

- កសិដ្ឋានគោ-ក្របីសាច់ កើន ១៩កន្លែង ស្មើនឹង ២៧, ៩%
- កសិដ្ឋានគោទឹកដោះ នៅ៤កន្លែងដដែល

២. ស្ថិតិគោ-ក្របីសរប កើន១១៩,៣% ក្នុងនោះ៖

- គោ-ក្របីសាច់ កើន ១២៧,៩%
- គោទឹកដោះ កើន ៦,៧%។

តារាងទី២.៣៖ កសិដ្ឋានចិញ្ចឹមគោ-ក្របី លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣

| កសិដ្ឋានចិញ្ចឹមគោ-ក្របី លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣ | | | | | ប្រៀបធៀប | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទផលិតកម្ម | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | | ប្រៀបធៀប (+/-) | | ភាគរយ (%) | |
| | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន | ចំនួនសត្វ |
| គោ-ក្របីសាច់ | 68 | 14.76 | 87 | 33.64 | 19 | 18.88 | 27.9% | 127.9% |
| គោ-ក្របីទឹកដោះ | 4 | 1.13 | 4 | 1.20 | 0 | 0.08 | 0.0% | 6.7% |
| **សរុប** | **72** | **15.88** | **91** | **34.84** | **19** | **18.95** | **26.4%** | **119.3%** |

ក្រាហ្វិកទី២.៩៖ កសិដ្ឋានចិញ្ចឹមគោ-ក្របី លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣




## ២.៦.៣. ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក

ចំពោះអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៦៤,៤% ក្នុងឆ្នាំ២០២២ ដល់ចំនួន៦៥,៤% នៅក្នុងឆ្នាំ២០២៣។ ដោយឡែកអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ បានថយចុះពីចំនួន ៣៥,៦% ក្នុងឆ្នាំ២០២២មកត្រឹមចំនួន៣៤,៦% នៅឆ្នាំ២០២៣។

ក្រាហ្វិកទី២.១០៖ បង្ហាញពីការប្រៀបធៀបបែបផែនផលិតកម្មជ្រូក ពីឆ្នាំ២០១៩-២០២៣



ក្រាហ្វិកទី២.១១៖ បង្ហាញពីក្រាហ្វិកប្រៀបធៀបអត្រានៃបែបផែនផលិតកម្មជ្រូក ពីឆ្នាំ២០១៩-២០២៣




ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ផលិតកម្មជ្រូកសរុបមានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺកើន ៦,៥% ឆ្នាំ ក្នុងនោះ

- ចំពោះផលិតកម្មជ្រូកលក្ខណៈគ្រួសារ មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺថយ ៥,៥% ក្នុងមួយឆ្នាំ
- ផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្ម មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺកើន ២៤,៥៩%

សម្រាប់ឆ្នាំ២០២៣នេះ ធៀបនឹងឆ្នាំ២០២២ ផលិតកម្មជ្រូកសរុបមានអត្រាកំណើន ៤,៥% ក្នុងនោះ៖

- ចំពោះផលិតកម្មលក្ខណៈគ្រួសារ មានអត្រាកំណើន ១,៦%
- ផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្ម មានអត្រាកំណើន ៦,០%។

បែបផែនផលិតកម្មជ្រូក៖

- អត្រានៃការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ បានថយពី ៣៥,៦% ក្នុង២០២២ ដល់ ៣៤,៦% នៅឆ្នាំ ២០២៣
- អត្រានៃការចិញ្ចឹមជ្រូកលក្ខណៈពាណិជ្ជកម្ម បានកើនពី ៦៤,៤% ក្នុង២០២២ ដល់ ៦៥,៤% នៅឆ្នាំ ២០២៣។

តារាងទី២.៤៖ បង្ហាញពីតារាងកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣

| កសិដ្ឋានចិញ្ចឹមជ្រូក លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣ | | | | | ប្រៀបធៀប | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទផលិតកម្ម | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | | ប្រៀបធៀប (+/-) | | ភាគរយ (%) | |
| | កសិដ្ឋាន (កន្លែង) | ចំនួនជ្រូក (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនជ្រូក (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនជ្រូក (ពាន់ក្បាល) | កសិដ្ឋាន | ចំនួនជ្រូក |
| ជ្រូកពូជ | 92 | 407 | 94 | 458 | 2 | 51 | 2.2% | 12.5% |
| ជ្រូកសាច់ | 514 | 1,804 | 520 | 1,886 | 6 | 83 | 1.2% | 4.6% |
| **សរុប** | **606** | **2,211** | **614** | **2,345** | **8** | **134** | **1.3%** | **6.0%** |

ផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០២៣៖

១. កសិដ្ឋានជ្រូក កើន ៨កន្លែង= ១,៣% ក្នុងនោះ៖

- កសិដ្ឋានជ្រូកពូជ កើន ២កន្លែង= ២,២%
- កសិដ្ឋានជ្រូកសាច់ កើន ៦កន្លែង= ១,២%

២. ស្ថិតិជ្រូកសរុប កើន ៦,០% ក្នុងនោះ៖

- ជ្រូកពូជ កើន ១២,៥%
- ជ្រូកសាច់ កើន ៤,៦%។

ក្រាហ្វិកទី២.១២៖ បង្ហាញពីកសិដ្ឋានចិញ្ចឹមជ្រូក លក្ខណៈពាណិជ្ជកម្មឆ្នាំ ២០២-២២០២៣





### ២.៦.៤. ការប្រៀបធៀបបែបផែនផលិតកម្មបក្សី

ចំពោះអត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៤១,៧% ក្នុងឆ្នាំ២០២២ ដល់ចំនួន៤២,១% នៅឆ្នាំ២០២៣។ ដោយឡែកអត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារបាន ថយចុះពីចំនួន ៥៨,៣% ក្នុងឆ្នាំ២០២២ មកត្រឹមចំនួន៥៧,៩% នៅឆ្នាំ២០២៣។

ក្រាហ្វិកទី២.១៣៖ បង្ហាញពីក្រាហ្វិកប្រៀបធៀបបែបផែនផលិតកម្មបក្សី ពីឆ្នាំ២០១៩-២០២៣




ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ផលិតកម្មបក្សីសរុបមានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺកើន ៩,៤៨%/ឆ្នាំ ចំពោះផលិតកម្មបក្សី លក្ខណៈគ្រួសារ មានអត្រាកំណើនមធ្យមប្រចាំឆ្នាំគឺកើន ៣,៦%/ឆ្នាំ ផលិតកម្មបក្សី លក្ខណៈពាណិជ្ជកម្ម មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ គឺកើន ២២,៩%/ឆ្នាំ។

សម្រាប់ឆ្នាំ២០២៣ បើធៀបទៅនឹងឆ្នាំ២០២២ ផលិតកម្មបក្សីសរុបមានអត្រាកំណើន ២,១% ក្នុងនោះ ÷ ចំពោះផលិតកម្មបក្សី លក្ខណៈគ្រួសារ មានអត្រាកំណើន ១,៤% ផលិតកម្មបក្សី លក្ខណៈពាណិជ្ជកម្ម មានអត្រាកំណើន ៣.០%។

- បែបផែនផលិតកម្មបក្សី៖

អត្រានៃការចិញ្ចឹមបក្សី លក្ខណៈគ្រួសារ បានថយពី ៥៨,៣% ក្នុង២០២២ ដល់ ៥៧,៩% នៅឆ្នាំ២០២៣ អត្រានៃការចិញ្ចឹមបក្សី លក្ខណៈពាណិជ្ជកម្ម បានកើនពី ៤១,៧% ក្នុង២០២២ ដល់ ៤២,១% នៅឆ្នាំ២០២៣

ក្រាហ្វិក២.១៤៖ បង្ហាញពីក្រាហ្វិកប្រៀបធៀបបែបផែនផលិតកម្មបក្សី ពីឆ្នាំ២០១៩-២០២៣




តារាងទី២.៥៖ បង្ហាពីកសិដ្ឋានចិញ្ចឹមបក្សីលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣



ក្រាហ្វិក២.១៥៖ បង្ហាញពីកសិដ្ឋានចិញ្ចឹមបក្សីលក្ខណៈពាណិជ្ជកម្មឆ្នាំ ២០២២-២០២៣

| កសិដ្ឋានចិញ្ចឹមបក្សី លក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២២-២០២៣ | | | | | ប្រៀបធៀប | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទផលិតកម្ម | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | | ប្រៀបធៀប (+/-) | | ភាគរយ (%) | |
| | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន (កន្លែង) | ចំនួនសត្វ (ពាន់ក្បាល) | កសិដ្ឋាន | ចំនួនសត្វ |
| មាន់សាច់ | 599 | 22,223 | 611 | 22,947 | 12 | 724 | 2.0% | 3.3% |
| មាន់ស៊ុត | 41 | 571 | 38 | 556 | -3 | -14 | -7.3% | -2.5% |
| មាន់ពូជ | 8 | 511 | 11 | 618 | 3 | 107 | 37.5% | 20.9% |
| ទាសាច់ | 1 | 20 | 0 | 0 | -1 | -20 | -100.0% | -100.0% |
| ទាស៊ុត | 78 | 814 | 69 | 790 | -9 | -24 | -11.5% | -2.9% |
| ក្រួច | 3 | 102 | 2 | 50 | -1 | -52 | -33.3% | -51.0% |
| **សរុប** | **730** | **24,240** | **731** | **24,961** | **1** | **720** | **0.1%** | **3.0%** |

➢ ផលិតកម្មបក្សីលក្ខណៈពាណិជ្ជកម្ម ក្នុងឆ្នាំ២០២៣

១. កសិដ្ឋានចិញ្ចឹមបក្សីសរុបកើន ១កន្លែង= ០,១% ក្នុងនោះ៖

- កសិដ្ឋានមាន់សាច់ កើន ១២កន្លែង=២,០%
- កសិដ្ឋានមាន់ស៊ុត ថយ ៣កន្លែង= -៧,៣%
- កសិដ្ឋានមាន់ពូជ កើន ៣កន្លែង= ៣៧,៥%
- កសិដ្ឋានទាស៊ុត ថយ ៩កន្លែង= -១១,៥%។

២. ស្ថិតិបក្សីសរុប កើន ៣,០% ក្នុងនោះ៖

- មាន់សាច់ កើន ៣,៣%
- មាន់ពូជ កើន ២០,៩%
- បក្សីផ្សេងទៀត ថយចុះ។



## ២.៦.៥. ការប្រៀបធៀបបែបផែនផលវារីវប្បកម្ម

យោងតាមការតារាងខាងក្រោមបានបង្ហាញអោយឃើញថាផលនេសាទទឹកសាបមានការកើនឡើងនឹងថយចុះ តាមឆ្នាំនីមួយៗ ជាក់ស្តែងការព្យាករណ៍ក្នុងឆ្នាំ២០១៩ ផលនេសាទទឹកសាបមានចំនួន ៥២៤,៤៦៥ តោន ទៅឆ្នាំបន្ទាប់ឆ្នាំ២០២០ ការនេសាទទឹកសាបបានថយចុះមកត្រឹម៤១៣,២០០តោន ចំពោះឆ្នាំ២០២១ ថយមកត្រឹម៣៨៣,០៥០តោន ចំណែកឆ្នាំ២០២២ ការនេសាទទឹកសាបបានកើនឡើងមកដល់៤០៦,៤០០ តោន និងឆ្នាំ២០២៣បានកើនដល់៤២៦,៧៥០តោន។

ចំណែកឯផលនេសាទទឹកសមុទ្រ ក្នុងឆ្នាំ២០១៩ មានចំនួន ១៣៧,២២៥តោន រីឯឆ្នាំ ២០២០ បានថយមកត្រឹម១២២,៧០០តោន ចំណែកឆ្នាំ២០២១ផលនេសាទទឹកសមុទ្របានកើនឡើងវិញកើនដល់១២៥,០០០ តោន ចំពោះឆ្នាំ២០២២ បានកើនដល់១២៥,២០០តោន និង២០២៣ កើនដល់១២៥,៥០០តោន។

ចំពោះផលវារិវប្បកម្ម តាមតារាងបានបង្ហាញអោយឃើញថាក្នុងឆ្នាំ២០១៩មានចំនួន ៣០៧,៤០៥តោន ឆ្នាំ២០២០កើនដល់ ៤០០,៤០០តោន ចំពោះឆ្នាំ២០២១ មានការធ្លាក់ចុះមកត្រឹម ៣៤៨,៣៥០តោន ចំណែកឆ្នាំ២០២២ថយមកត្រឹម៣៣០,៦០០តោន និងឆ្នាំ២០២៣ថយមកត្រឹម៣១៤,០០០តោន។

ក្រាហ្វិកទី ២.១៦៖ បង្ហាញពីផលនេសាទទឹកសាប ទឹកសមុទ្រ និង វារីវប្បកម្ម (តោន)




## ២.៧. តម្រូវការសត្វ និងសាច់សត្វ

ក្នុងឆ្នាំ១៩៩៣ ការបិភោគសាច់សត្វមានចំនួន១៥.១៤% ចំណែកឆ្នាំ១៩៩៨ ការបិភោគសាច់សត្វបានកើនឡើងដល់១៥.១៧%។ ចំពោះឆ្នាំ២០០៣វិញ កំណើននៃការបិភោគសាច់សត្វបានកើនឡើងដល់

១៥.៩៩% បើយើងក្រឡេកមកមើលឆ្នាំ២០០៨ កំណើននៃការបរិភោគសាច់សត្វបានកើនឡើងដល់១៦.០១% ប៉ុន្តែបើយើងក្រឡេកមកមើលឆ្នាំ២០១៣ ការបរិភោគសាច់សត្វបានធ្លាក់ចុះមកត្រឹមតែ១៣.២១%។ រីឯការបរិភោគសាច់សត្វក្នុងឆ្នាំ២០១៨ ឃើញថាមានការកើនឡើងដល់១៧.៦០%ហើយចំពោះឆ្នាំ២០២៣ កំណើននៃការបរិភោគសាច់សត្វបានកើនឡើងដល់១៨.៥០%។ បើមើលតាមក្រាហ្វិកខាងក្រោមប្រជាជនកម្ពុជានិយមបរិភោគសាច់ជ្រូក និងសាច់គោ។

ក្រាហ្វិកទី២.១៧៖ បង្ហាញពីការបរិភោគសាច់សត្វក្នុងមនុស្សម្នាក់ ក្នុង១ឆ្នាំ




ក្រាហ្វិកទី២.១៨៖ បង្ហាញពីតម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាតក្នុងរយៈពេល៣០ឆ្នាំ (១៩៩៣-២០២៣)



ក្រាហ្វិកទី២.១៩៖ បង្ហាញពីអត្រានៃការផ្គត់ផ្គង់ និងកង្វះខាតក្នុងរយៈពេល៣០ឆ្នាំ (១៩៩៣-២០២៣)




➢ ចំពោះតម្រូវការប្រើប្រាស់ និងការផ្គត់ផ្គង់ ក្នុងឆ្នាំ២០២៣

១. តម្រូវការប្រើប្រាស់សាច់សរុប ៣២៧ពាន់តោន ក្នុងនោះ÷

- សាច់គោ-ក្របី ៩១ពាន់តោន (៨២៨ពាន់ក្បាល/ឆ្នាំ ឬ ២ ២៦៨ក្បាល/ថ្ងៃ)
- សាច់ជ្រូក ១៦៥ពាន់តោន (៣, ៣១លានក្បាល/ឆ្នាំ ឬ ៩ ០៦៨ក្បាល/ថ្ងៃ)
- សាច់បក្សី ៦៩ពាន់តោន (៥៨,១៨លានក្បាល/ឆ្នាំ ឬ ១៥៩ពាន់ក្បាល/ថ្ងៃ)។

២. លទ្ធភាពផ្គត់ផ្គង់សាច់សរុប ៣២០ពាន់តោន ស្មើនឹង ៩៨%

- សាច់គោ-ក្របី ៨៩ពាន់តោន (៨១៦ពាន់ក្បាល/ឆ្នាំ ឬ ២ ៥០៩ក្បាល/ថ្ងៃ)
- សាច់ជ្រូក ១៦៥ពាន់តោន/ឆ្នាំ (៣, ៣១លានក្ប./ឆ្នាំ ឬ ៩ ០៦៨ក្បាល/ថ្ងៃ)
- សាច់បក្សី ៦៥ពាន់តោន (៥៤លានក្បាល/ឆ្នាំ ឬ១៤៨ពាន់ក្បាល/ថ្ងៃ)។

ដោយនៅប្រទេសកម្ពុជាមានប្រជាជនកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ដែលជាហេតុធ្វើអោយមានតម្រូវការស្បៀងអាហារកាន់តែច្រើនឡើងទៅៗ និងមានការបរិភោគសាច់ជាអាហារផងដែរ។ការបរិភោគសាច់សត្វនៅកម្ពុជាមនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៨គីឡូក្រាម ក្នុងនោះមានសាច់គោ ក្របីចំនួន ០៥គីឡូក្រាម សាច់ ជ្រូកចំនួន៩.២៩គីឡូក្រាម សាច់បក្សីចំនួន៣,៦៩គីឡូក្រាម និងសាច់ចៀម ពពែចំនួន ០,០២គីឡូក្រាម។

## ២.៨. ការអភិវឌ្ឍន៍វិស័យកសិកម្មតាមរយៈការចិញ្ចឹមសត្វ

### ២.៨.១. ការជំរុញសុខភាពសត្វ

ឆ្នាំ២០២១ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានធ្វើការចុះត្រួតពិនិត្យនិង ទប់ស្កាត់បទល្មើសចរាចរណ៍សត្វ និងការធ្វើអាជីវកម្មសត្វ ដោយបានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធបានបន្តអនុវត្តសេចក្តីណែនាំអំពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូលនាំចេញ និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ។ ដូច្នេះនៅទូទាំងប្រទេសបានធ្វើការ ត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វចំនួនសរុប២០២ករណី ក្នុងនោះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន១១៤ករណី និង បង្ក្រាបបទល្មើសបានចំនួន៥៦ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១៨ករណី ជ្រូករស់ចំនួន២៤ករណី សាច់ជ្រូកបង្កក ចំនួន០២ករណី សាច់ក្រូចបង្កកចំនួន០២ករណី ប្រហិតចំនួន០៤ករណី ស្លាបមាន់និងជើងមាន់ចំនួន០២ករណី សាច់ គោ ក្របីចំនួន០២ករណី គ្រឿងក្នុងជ្រូកចំនួន០២ករណី) និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត បង្ក្រាបបទល្មើសបានចំនួន៣២ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១២ករណី ជ្រូករស់ចំនួន០៧ករណី និងផលិតផល កែច្នៃពីសត្វចំនួន១៣ករណី)។ ជាមួយគ្នានេះដែរ បានធ្វើការអង្កេតតាមដានបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លង សត្វ ព្រមទាំងបានរៀបចំប្រព័ន្ធព័ត៌មាន និងរាយការណ៍ជំងឺឆ្លងសត្វទាំងថ្នាក់ជាតិ និងអន្តរជាតិ ចាត់វិធានការណ៍ ជីវសុវត្ថិភាព និងកម្មវិធីឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺឆ្លងសត្វ។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០២១ រួមមាន៖

**១**.ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលកើតមានលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់ សារទឹក និងជំងឺដុំពកស្បែកគោ ក្របីចំនួនសរុប៩៥០ ៨៨៩ក្បាល ចាក់វ៉ាក់សាំងការពារជំងឺលើជ្រូកចំនួន ២ ២១០ ៦២២ ក្បាល ចាក់វាក់សាំងការពារជំងឺលើបក្សីបានចំនួន៣៨ ៧៧៤ ៤៧១ក្បាល និងចាក់វ៉ាក់សាំងការពារជំងឺលើឆ្កែ និង ឆ្មាចំនួន១១ ៧១៣ក្បាល។

**២**.ចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារសត្វ កសិដ្ឋានចិញ្ចឹមសត្វកន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន ២០២ ០២៤លើក។

**៣**.ក្នុងឆ្នាំ២០២១ ភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេសមានចំនួន៩ ២៦២ នាក់ ក្នុងនោះស្រី ៧២២ នាក់។

### ២.៨.២. ការពង្រឹងសុខភាពសាធារណៈបសុពេទ្យបាល

សម្រាប់សុខភាពសាធារណៈបសុព្យាបាលជាផ្នែកមួយយ៉ាងសំខាន់ដែលមានភារៈកិច្ចក្នុងការវាយតម្លៃ និងផ្តល់ការអនុញ្ញាតបង្កើតសត្តឃាតដ្ឋាននិងកន្លែងកែច្នៃសាច់ និងផលិតផលសត្វ ដែលធ្វើយ៉ាងណាធានានូវសុខភាពសាធារណៈ តាមរយៈការពង្រឹងការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យផលិតផល សាច់ និងសត្វ។ ក្នុងនោះផងដែរមានអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ចុះផ្សព្វផ្សាយច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ អនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ខ្ពស់ រៀបចំចងក្រងឯកសារបច្ចេកទេស នានា និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសត្វ ផលិតផលសត្វ ការពិឃាតសត្វតាម បទដ្ឋានបច្ចេកទេសដល់អ្នកពាក់ព័ន្ធ ព្រមទាំងបានបំពាក់បំប៉នបង្កើនសមត្ថភាពដល់មន្ត្រីប្រចាំការនៅតាមសត្តឃាតដ្ឋាន និងអ្នកពាក់ព័ន្ធលើជំនាញត្រួតពិនិត្យសុខភាពសត្វ អនាម័យសាច់ និងផលិតផលសត្វផងដែរ។

នៅក្នុងឆ្នាំ២០១៩ សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន២២៥កន្លែង ក្នុងនោះមាន សត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨ មានចំនួន១១៦កន្លែង សត្តឃាតដ្ឋានអនុក្រឹត្យ១០៨ និងវិនិយោគចំនួន ៥១កន្លែង និងសត្តឃាតដ្ឋានវិនិយោគចំនួន៥៨កន្លែង ក្នុងនោះសត្តឃាតដ្ឋានពិឃាតគោទំនើបលំដាប់អន្តរជាតិនៅខេត្តតាកែវចំនួន០១កន្លែង និងសត្តឃាតដ្ឋានពិឃាតបក្សីទំនើបនៅខេត្តកណ្តាលចំនួន០១កន្លែង។ បើទោះបីសត្តឃាត ដ្ឋានកើនជាលំដាប់ ប៉ុន្តែចំនួននេះមិនទាន់គ្រប់គ្រាន់ទាំងបរិមាណ និងមិនអនុលោមតាមច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តពាក់ព័ន្ធលើការបង្កើត និងគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វនៅឡើយ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនឹងខិតខំណែនាំបទដ្ឋានបច្ចេកទេសអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វបន្ថែមទៀត។[18]

[18] ឯកសារយោង៖ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ( *របាយការណ៍បូកសរុបការងារសុខភាពសត្វ និងផលិតកម្មប្រចាំឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០*) ទំព័រទី ១៧។

### ២.៨.៣. កម្មវិធីកែលម្អពូជ

សម្រាប់ការកែលម្អពូជសត្វ និងផលិតកម្មសត្វ បានធ្វើការផ្សព្វផ្សាយអំពីបច្ចេកទេស និងអំពីអត្ថប្រយោជន៍នៃការបង្កាត់ពូជគោ និងជ្រូកដោយសិប្បនិម្មិតទៅដល់មន្ត្រីជំនាញនៃផ្នែកផលិតកម្មសត្វ និងបសុព្យាបាលនៅក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ការកែលម្អពូជត្រូវបានធ្វើឡើយដោយជ្រើសរើសពូជមេបាល្អៗ ដែលយកមកបង្កាត់តាមរយៈការបង្កាត់ដោយសិប្បនិម្មិត ហើយនាំយកពូជមេជីវិត និងពូជសត្វល្អៗពីបរទេស ដែលយកមកបង្កាត់ជាមួយពូជក្នុងស្រុក ដើម្បីអោយមានការបន្សុំទៅនឹងអាកាសធាតុផងដែរ។

- ក្នុងការកែលម្អពូជសត្វ សម្រាប់ការងារសំខាន់ៗចំនួន ៣ ដែលគម្រោងនឹងត្រូវអនុវត្តចំពោះមុខគឺៈ

